

# ក្រូធំបង្គុំស់នៅក្នុងទម្រង់សិល្បៈល្ខោន និងវេជ្ជសាស្ត្រខ្មែរបុរាណ

រៀបរៀងដោយ ហ៊ឹម ធត្យបញ្ញា

ព.ស ២៥៦០ គ.ស ២០១៦

# ជំពូក១    សេចក្តីផ្តើម

សព្វថ្ងៃយើងតែងលឺគេហៅទៅរកបុគ្គលណាម្នាក់ដែលមាន ចំណេះខ្ពង់ខ្ពស់ ហើយយកចំណេះដឹងទាំងនោះ មកជួយណែនាំ ពន្យល់បង្ហាត់បង្ហាញ ដល់មនុស្សទូទៅមិនថាក្មេង មិនថាចាស់អោយ តែមានបំណងប្រាថ្នាចង់ចេះ ចង់ដឹងចង់ស្វែងយល់ពីអ្វីមួយ ។ អ្នក ដែលជួយតម្រែតម្រង់នោះ គេតែងហៅបុគ្គលនោះថា"គ្រូ" ។បើ យោងតាមវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត "គ្រូ" ជា ពាក្យបាលីនឹងសំស្ក្រឹតក្លាយមកពីពាក្យថា គរ>គ្រ+ុ>ូ=គ្រូ ប្រែថា អ្នកដែលមានចិត្តធ្ងន់ អ្នកដែលគួរអោយគោរព អ្នកដែលបង្ហាត់ បង្រៀនចំនេះវិជ្ជា សិល្បសាស្ត្រផ្សេងៗដល់សិស្សដូចជាគ្រូអក្សរ គ្រូ លេខ គ្រូភ្លេង គ្រូបំបួស ជាដើម។[1]

បើយើងនិយាយពីគ្រូបុរាណាចារ្យ លោកតែងពោលថា រឿងអ្វីៗទាំងអស់ សុទ្ធតែមានគ្រូជាអ្នកបង្ហាត់បង្រៀន បើសិនណា រៀនឥតមានគ្រូទេ នាំអោយវិនាសខ្លួនឯង ដូចជាអ្នករៀនកម្មដ្ឋាន ពេលណារៀនមិនរកគ្រូអោយដឹកនាំចម្រើនត្រឹមត្រូវទេ អាចទៅជា

---

[1] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជជួន ណាត.១៩៦៧

ឡប់សតិ វិកលចរិក ឬយ៉ាងខ្លីថាបែកកម្មដ្ឋាន ដោយសារតែមិនមាន គ្រូដឹកនាំត្រឹមត្រូវ។នៅក្នុងផ្នត់គំនិតរបស់ខ្មែរយើងមុននឹងរៀនសូត្រ ពោលហាស្តីនូវពាក្យអប់រំទូន្មានឬប្រារព្ធអ្វីមួយគេតែងរំលឹកដល់" គ្រូ"ដើមរបស់ខ្លួនជានិច្ចជាកាលមិនអាចខកខានបានឡើយ បើមិន ដូច្នោះទេការងារ ការរៀនសូត្រការពោលស្តីមិនសូវជាបានផលល្អ ប៉ុន្មានទេ បើនិយាយពីផ្នែកពុទ្ធចក្រវិញមុនពេលព្រះសង្ឃទេសនា ត្រូវតាំងនមោ ៣ចប់ជាការមនស្សការចំពោះព្រះពុទ្ធ បញ្ញាធិក វិរិយាធិក សមាធិក រួចចាប់ ផ្តើមបទបរិយាយតាមអត្ថនៃធម៌ ដែល លោកចង់សម្តែង។នៅក្នុងច្បាប់ចាស់ៗពីបុរាណ មុនពេលលោក លើកឡើងជាច្បាប់ល្បើក លើកមកនិទានចែកផ្សាយដល់អ្នកស្តាប់ លោកតែងមិនភ្លេចរព្ញកគុណគ្រូឧបជ្ឈាយាចារ្យ មាតាបិតាជាមុន សិន ទើបចាប់ផ្តើមនិទានពីល្បើកពីច្បាប់នោះ។ឧទាហរណ៍នៅក្នុង សាស្ត្រារឿង ហ៊ាន ប៊ុន តែងដោយកវីក្មួយម្នាក់នៅស.វទី១៩ មុននឹង និទានលោកលើកឡើងបង្ហាញ ឈ្មោះនឹងរំឭកចំពោះគ្រូរបស់គាត់។

អបំនាមខ្ញុំ ក្មួយកើតស្រុកភ្នំ ពេញ
ពូជហុកក្មៀន រៀនវត្តស្រះចកគ្រូយក
ទៅប្រៀន ប្រដៅអោយរៀន

នមោ ក ខ ។

គ្រូលោកមានងារ ជាព្រះសាងនា
យកលោកប្រៀបប្រដៅ នៅជេរវាយដំ
អោយខ្ញុំរៀនរក ខ្ញុំលុតលើកករ

ថ្វាតថ្វាយវន្ទា។[២]

ចំណែកវត្តប្រតិបត្តិចំពោះគ្រូវិញ ខ្មែរយើងក៏មានការគោរពខ្លាំងខ្លាណាស់ ទុកស្មើនឹងឪពុកនឹងម្តាយរបស់យើង។ឧទាហរណ៍នេះជាសម្រង់ខ្លះៗ អំពីអំពីច្បាប់ក្រមដែលទាក់ទងនឹងការគោរពប្រតិបត្តិគ្រូ។

កុំធ្វើវាយមាយ នឹងគ្រូបាធ្យាយ
ទុកស្មើអម្ចាស់ សង្វាតសរសេរសូត្រ
រៀនអោយណាស់ ប្រាជ្ញាយល់ច្បាស់

នាំញតិទាំងឡាយ។[...]

អាសូរមេបា ចិញ្ចឹមរក្សា
ពុំអោយអន្តរាយ អាចយកមកផ្ញើនឹង
គ្រូបាធ្យាយ ហេតុចង់ពណ្ណរាយ

ប្រយោជន៍ទាំងបី។[...]

---

២ មាលីអក្សរសិល្បខ្មែរ ស.វ១៩ ឃីង ហុកឌី

[...] វិគ្រូបាធ្យាយ ប្រដូចនឹងម្ដាយ
ឪពុកឯងហោង ហ្វឹកហ្វឺនប្រដៅ
មិនអោយមានឆ្គង តាមដោយគន្លង
ព្រេងព្រឹទ្ធបុរាណ។

[...] នាបីហៅគ្រូ ដូចអ្នកនាំផ្លូវ
ដើរដោយគន្លង ទោះនឹងឆ្ពោះទៅ
ស្រុកតូចធំផង សឹងដូចបំណង
នៃចិត្តចិន្តា។[...]

[...] ពុំដឹងដើមគ្រូ បង្កើតអភិរូហ៍ប្រដូចនូវ
ម្ដាយ ភ្លីពីមនុស្សលោក
រួចដល់សួគិ៍នាយ ចៀសចតុរាបាយ
នរកទាំងបួន។[៣]

នៅច្បាប់ក្រមខាងលើនេះ គឺចង់បង្ហាញពីការប្រដូចគ្រូទៅនឹងអម្ចាស់ដែលជាអ្នកមានអំណាច កាន់កាប់អ្វីៗដែលជារបស់ខ្លួន ឬក៏ជាឥស្សរលើបុគ្គលជាសិក្ខាកាម គឺជាសិស្សដែលបានមកចូលរៀនក្នុងសំណាក់គ្រូណាម្នាក់។ បើយើងសំលឹងអោយវែងឆ្ងាយ គ្រូ

៣ ច្បាប់ផ្សេងៗ ពុទ្ធសាសនបណ្ឌិត្យ១៩៧៤

ពិតជាមានឥទ្ធិពលពិតជាឥស្សរលើកូនសិស្សខ្លួនប្រាកដណាស់ តួយ៉ាងខ្មែរពីបុរាណតែងនិយាយពាក្យមួយឃ្លាថា "**ជំងាយគ្រូម្តាយជា**" មានន័យថា ពាក្យសម្តីគ្រូក៏ដូចជាសម្តីម្តាយឪពុកដែរ គេមានតំណាមមួយ គឺមិនអោយម្តាយឪពុកដាក់ទំនាយកូនទេព្រោះពាក្យនោះក្លាយជាពាក្យពិត ហើយអ្វីដែលម្តាយឪពុកហាមប្រាមវិញ កូនត្រូវតែងគោរពតាម ប្រតិបត្តិតាម ដូចគ្នាប្រសិនបើយើងបដិសេធមិនស្តាប់តាមពាក្យរបស់គ្រូ ជំទាស់ជាមួយគ្រូ អាចក៏នាំមកនូវសេចក្តីសាបសូន្យជាក់ជាមិនខានឡើយ។ ទុំស្លាប់ដោយសារមិនស្តាប់សម្តីគ្រូ ដោយសារតែចិត្តក្តៅរោលរាល ដោយភ្លើងរាគទុករាលពេញរហូតទ្រាំមិនបានទៅលួចសឹកនៅក្រោមដើមពោធិ៍ ប្រឆាំងជម្នះនឹងពាក្យគ្រូលទ្ធផលទីបញ្ចប់ទុំត្រូវស្លាប់យ៉ាងវេទនា។ បន្ថែមពីការទាក់ទងនឹងគ្រូដដែល ខ្មែរយើងបានចងជាប្រស្នាមួយចំនួននឹងសុភាសិតខ្លះៗ ជុំវិញបញ្ហារបស់គ្រូ។ ប្រស្នាមួយគេលើកឡើងថា បើម្តាយនឹងគ្រូត្រូវលង់ទឹក តើយើងត្រូវជួយអ្នកណាមុន ? ចម្លើយដ៏ត្រឹមត្រូវគឺយើត្រូវជួយស្រង់គ្រូមកមុនព្រោះថា គ្រូអាចជួយរកល្បិចកិច្ចកលផ្សេងៗដើម្បីជួយម្តាយ ជួនកាលគ្រូអាចចេះប្រោសអោយជីវិតម្តាយរស់ឡើងវិញក៏អាចថាបាន មួយទៀតបើគ្រូគាត់មានជីវិតដ៏រាបណា ដរាបនោះគាត់នៅតែអាច ប្រៀបប្រដៅយើងនូវវិជ្ជាចំណេះជំនាញគ្រប់បែបយ៉ាង ។ បំរៀបន័យបុរាណមួយលោកលើកថា ម្តាយឪពុកជាអ្នកបង្កើតកូន នឹងបើកភ្នែកទីមួយអោយកូន ប៉ុន្តែគ្រូជាអ្នកបើកភ្នែកទីពីរអោយកូន នេះចង់បញ្ជាក់ថា គ្រូពិតជាមាន

តម្លៃ ស្មើនឹងឪពុកម្តាយ និយាយរួមមក គ្រូដែលខ្មែរដែលធ្លាប់កប់ប្រសព្វ ធ្លាប់ស្គាល់មានច្រើនបែបច្រើនយ៉ាងណាស់អ្វីដែលខ្ញុំនឹងលើកយកមកបង្ហាញនេះគឺខ្ញុំផ្តោតសំខាន់ទៅលើគ្រូសិល្បះ វេជ្ជសាស្ត្រ ក្នុងសង្គមខ្មែរបុរាណ។ នៅក្នុងទីនេះខ្ញុំមានចង់បំណងបកស្រាយរកអោយឃើញថា តើនរណាជាគ្រូធំជាងគេបង្អស់ក្នុងវិស័យខាងលើនេះ?។ ធម្មតាអ្វីៗទាំងអស់ក្នុងលោកនេះសុទ្ធតែបង្រៀនដោយគ្រូទាំងអស់ ហើយគ្រូដែលបង្រៀនចំណេះវិជ្ជាទាំងនោះ គាត់ចេះតពីគ្រូរបស់គាត់ ឯគ្រូរបស់គាត់គឺចេះតពីគ្រូរបស់គាត់ ដូចច្នេះគ្រូរៀនតពីគ្រូមួយទៀត ឯគ្រូទាំងនោះសុទ្ធតែរៀនតៗគ្រូ ដូច្នេះ គ្រូដំបូងគេបង្អស់នោះជានរណា?

# ជំពូក២ល្ខោនក្បាច់បុរាណ

## I. ប្រវត្តិកំណើតក្បាច់បុរាណ

*តាំងតែពីបុរាណាចារ្យ ពេលមានពិធីបុណ្យធំៗ ដូចជាបូជាព្រះសព លើកព្រះសពព្រះគ្រូចៅអធិការ បញ្ចុះសីមា ជាពិសេសពិធីបុណ្យចូលឆ្នាំថ្មី គេច្រើនតែមានរបាំបុរាណយកទៅរាំមាន ល្ខោនខោល ល្ខោនស្បែកធំល្ខោនស្បែកតូចជាដើម។ សិល្បៈទាំងអស់នេះគេច្រើនតែក្នុងសម្តែងវត្តរឬបុណ្យជាតិធំម្តងម្កាល ប៉ុន្តែត្រកូលអភិជនមួយចំនួនពេលប្រារព្ធពិធីបុណ្យនៅតាមផ្ទះមាន បុណ្យបច្ច័យបួន ច័ន្ទសុខគិរីសូត្រ ជីវទាន ឆាកមហាបង្សុកូល គេអាចជួល ល្ខោនរបាំបុរាណទាំងនេះ ទៅសម្តែងតាមការនិយមរបស់បុគ្គលម្នាក់ៗ។ ចំពោះការនិយមបែបនេះកើតឡើងតាំងពីយូរណាស់មកហើយ នៅនាសម័យបុរាណមកម្ល៉េះតែគេមិនមែនសម្តែងអោយមនុស្សមើលនោះទេ គឺគេរាំសម្រាប់ថ្វាយទេព ដែលគង់ក្នុងទេវស្ថាន ។ បើយើងនិយាយពីកំណើតក្បាច់បុរាណទាំងអស់នេះវិញ ក៏មិនមែនទើបតែកើតចន្លោះ២ទៅ៣ស.វមុននេះឡើយ។ យើងអាចនិយាយបានថាទម្រង់សិល្បៈរបាំក្បាច់បុរាណទាំងអស់នោះវាប្រហែលយោងយកកំណើតនៅសម័យនគរភ្នំស.វទី៦ នៃគ្រិស្តសករាជ បើមិនដូច្នោះទេក៏កើតក្នុងសម័យចេនឡាស.វទី៨នៃគ្រិស្តដែរ មានន័យប្រាកដជាកើតនៅមុនសម័យអង្គរជាដាច់ខាត ដោយសារតែយើងបានរកឃើញចម្លាក់ស្រីរាំរបាំនឹងហនុមានធ្វើពីដីដុតនៅក្នុងបរិវេនវត្តគំនូរ*

ដែលស្ថិតនៅចំកណ្តាលរាជធានីអង្គរបុរីទាំងមូល។ ម៉្យាងទៀតនៅលើសិលាចារឹកK៥៥៧ K៦០០នឹង K១៣៧ គេរកឃើញនៅវត្តគំនូរជា សិលាចារឹករបស់ព្រះបាទជ័យវរ្ម័នទី១ដែលបានរៀបរាប់ពីដង្វាយជាអ្នកច្រៀងរបាំនឹងឧបករណ៍ភ្លេង នៅទីនោះ។[៤] នេះសបញ្ជាក់អោយឃើញថាល្ខោនក្បាច់បុរាណទាំងអស់នេះកកើតឡើងតាំងពីសម័យមុនអង្គរមកម្លេះ។

## II. ការវិវត្តន៍ល្ខោនក្បាច់បុរាណ

ចាប់ពីសម័យអង្គរចូលមកដល់គឺក្នុងរាជរបស់ព្រះបាទជ័យវរ្មនទី២(៨០២ ៨៥០)ដែលជាក្សត្រ បានរំដោះប្រទេសខ្មែរ អោយរួចពីកណ្តាប់ដៃរាជវង្ស **សៃលេន្ទ្រ**ដោយប្រារព្ធពិធីទេវរាជនៅលើភ្នំមហេន្ទ្របពិត(ភ្នំគូលែន)។ នៅពេលនោះឯង សាសនាព្រាហ្មណ៍មានឥទ្ធិពលយ៉ាងខ្លាំងទៅលើព្រះរាជានឹងប្រជានុរាស្ត្រទូទាំងនគរ ដូច្នេះហើយការគោរពជឿលើអាទិទេពក៏មានការគោរពខ្លាំង ជាពិសេសគ្រិះអរិយធម៌សម័យនោះគឺ **កាម្រដ៍តេជ៍ជកតិតរាជ** (ទេពនៃព្រះរាជា) ដែលបានជាខឿនវប្បធម៌ថ្មីមួយសម្រាប់ក្សត្រជំនាន់ក្រោយៗទៀតយកគំរូរតាម មានការកសាងប្រាសាទឧទ្ទិសអាទិទេពជាដើម។ កាលណាការកសាងប្រាសាទកាន់តែច្រើនគេជឿ

---

៤ ទស្សនីភាពខ្មែរ គណៈកម្មការស្រាវជ្រាវសិល្បះវប្បធម៌ ២០០៣

ថា ល្ខោនក្បាច់បុរាណ ក៏កាន់តែរីកចម្រើន ដូចបានជម្រាបពីខាងដើមម្តងហើយថាប្រាសាទគឺជាទីលំនៅរបស់ទេព ហើយជាកន្លែងដែលគេត្រូវសម្តែងរបាំថ្វាយទេពទតកម្សាន្តដែរ។ ស្របគ្នានឹងការរុងរឿងនៃអរិយធម៌នេះ យើងពិនិត្យមើលតាមប្រាសាទមួយចំនួនដូចជា **បន្ទាយស្រី** (**ត្រីភួនមហេស្វរ**) ជាអលង្ការដ៏ប្រណិតនៃសិល្បៈ ដែលកសាងដោយ**ព្រះគ្រូយជ្ញវរាហ** ក្នុងគ.ស៩៦៧ និងនៅតាមជញ្ជាំងនៃប្រាសាទអង្គរវត្ត កសាងដោយ**ព្រះបាទសូរ្យវរ្ម័នទី២** ក្នុងគ.ស១១១៣គេឃើញមានចម្លាក់ស្រីរបាំនៃស្ថានសួគ៌ដែលទេពអប្សរ នៅគ្រប់តួប្រាង្គកំផែងប្រាសាទទិសទាំងបួនខាងក្រៅ ហូតដល់បណ្ណាល័យ ចំណែកឯខាងក្នុងប្រាសាទវិញ ចាប់កំផែងរហូតដល់ខាងលើប្រាសាទខាងលើកំពូលនៅលើប្រាសាទមានរូបស្រីរបាំច្រើនណាស់ស្ទើររាប់មិនអស់ ទាំងអស់នោះយើងអាចសន្និដ្ឋានបានថាភាពរីកនៃក្បាច់បុរាណបានដុះដាលខ្លាំងក្លាយ៉ាងជាទីមោទនៈដ៏អស្ចារ្យក្រៃលែងណាស់នាសម័យនោះ។

លុះមកដល់សម័យចុងអង្គរ ពោលគឺរាជកាល**ព្រះបាទជ័យវរ្ម័នទី៧** ប្រទេសខ្មែរបានផ្លាស់ប្តូរពីព្រាហ្មណ៍សាសនាមកកាន់ព្រះពុទ្ធសាសនាវិញក៏ពិត តែយើងសង្កេតឃើញថា ល្ខោនក្បាច់បុរាណខ្មែរ ក៏រីកចម្រើនដដែលទោះបីជាមានការកែទម្រង់សាសនាក៏ដោយ ក៏គេនៅតែយកទម្រង់សិល្បៈនេះទៅបម្រើអោយក្នុងលទ្ធិពុទ្ធរាជវិញម្តង ។ ក្នុងសិលាចារឹកនៅប្រាសាទតាព្រហ្មដែល ក

សាងឡើងនៅឆ្នាំ១១៩៣ ថ្វាយចំពោះព្រះមាតា នឹងព្រះរាជគ្រូដែលមានស្នងដោយបដិមា **ប្រាជ្ញាបារមី** ។សិលាចារឹកនោះបានបញ្ជាក់ថាដង្វាយជាស្រីរបាំចំនួន៦១៥នាក់។ឯប្រាសាទព្រះខ័នវិញ កសាងឡើងនៅឆ្នាំ១១៩១ឧទ្ទិសចំពោះព្រះបិតា ក៏មានសិលាចរឹកបញ្ជាក់ដែរថាមានស្រីរបាំរហូតដល់១០០០នាក់សម្រាប់រាំថ្វាយក្នុងពិធីសក្ការបូជាផ្សេងៗ ក្នុងប្រាសាទនេះ។លើពីនេះទៅទៀតពេលព្រះអង្គតែងតាំង**ព្រះនាងឥន្ទ្រទេវី**ជាបរិនាយកាចារ្យនៅមហាវិទ្យាល័យជ័យស្រី ទ្រង់បាននាំស្រីរបាំដែលជាព្រះរាជបរិពាររបស់ទ្រង់ទៅសម្តែងរឿងជាតកផ្សេងៗទៀតផង។

លុះមកដល់រាជ**ព្រះបាទជ័យវរ្ម័នទី៨** **ព្រះបាទស្រីន្ទ្រវរ្ម័ន** **ព្រះបាទឥន្ទ្រជ័យវរ្ម័ន** **និងព្រះបាទជ័យវរ្ម័នទី៩**រហូតមកដល់បដិវត្តត្រសក់ផ្អែម និងការរុករានពីសំណាក់សៀម បានធ្វើអោយវប្បធម៌សព្វបែបយ៉ាង និងធនធានមនុស្សទៀតផងចំណែកល្ខោនក្បាច់បុរាណក៏ត្រូវបាត់បង់។

ចំណេរក្រោយមកទៀតដល់រាជ **ព្រះបាទច័ន្ទរាជា** (១៥១៦–១៥៦៦) ជាពេលដេលខ្មែរប្រឹងងើបឡើងវិញដើម្បីទៅស្ដាបនាក្រុងអង្គរ បាខែងនឹងគូលែនជាបន្តទៀត។ហើយទ្រង់ ក៏បានយកចិត្តទុកដាក់រៀបចំឡើងវិញ នូវរាល់វប្បធម៌ សេដ្ឋកិច្ច សាសនា ឯកសារមួយបាននិយាយពីការយកព្រះទ័យទុកដាក់របស់ព្រះអង្គទៅលើ

ផ្នែកសិល្បៈ គ្រប់ផ្នែកមាន ល្ខោន តន្ត្រី របាំសម្រាប់សម្តែងអោយភ្ញៀវកិត្តិយស មន្ត្រីជាន់ខ្ពស់ទស្សនា។ ប៉ុន្តែជាអកុសលក្រោយរាជ្យ **ព្រះចាន់ច័ន្ទរាជា** លង្វែកជាបន្ទាយដ៏រឹងមាំរបស់ខ្មែរក៏រលាយដោយសារសៀមហើយ ទីបំផុតរាជធានីនេះត្រូវរលាយជាផេះផង់សារជាថ្មីនៅឆ្នាំ១៥៩៣នៃគ.ស។

ក្រោយសម័យនេះមកសិល្បៈក្បាច់បុរាណតែងតែមានវត្តមានជានិច្ច នៅក្នុងព្រះបរមរាជវាំង។ រហូតដល់រជ្ជកាល **ព្រះរាជសម្ភារ ព្រះចាន់ឧទ័យ** បានលើករាជធានីទៅកោះឃ្លោកដោយប្រហែលជានាំមកនូវក្រុមសិល្បៈក្បាច់ខ្មែរបុរាណ ជាក្រុមសម្តែងព្រះរាជទ្រព្យ មួយក្រុមមកជាមួយផង។ ព្រោះក្រោយពីការសិក្សាស្រាវជ្រាវទម្រង់ សិល្បៈខ្មែរឃើញថា ទំនងមានគ្រូដែលសេសសល់ទៅបង្រៀន **ល្ខោនពោលស្រី**[៤] នៅម្តុំកៀនស្វាយកោះស្លាកែតលុះរាជកាល**ព្រះចាន់សីហនុវរ្ម័ន** ទើបមានគ្រូដើរបង្ហាត់បង្រៀនល្ខោនក្បាច់បុរាណនេះនៅក្នុងសាលានានា នៅក្រុងភ្នំពេញកន្លែងបង្ហាត់ល្ខោនក្បាច់បុរាណ នេះមានដូចជានៅសាលាបឹងកេងកង (សព្វថ្ងៃមន្ទីរឃុំឃាំងទួលស្លែង) មានអ្នកម្នាងជាសាម៉ីជាអ្នកបង្រៀនផ្ទាល់។ ហើយពេលនោះព្រះបរមរាជវាំង ក៏បើកបង្រៀនល្ខោនក្បាច់បុរាណនេះឡើងដោយ **ព្រះមហាក្សត្រិយានីកុសមៈនារីរតន៍សិរីវឌ្ឍនា** ជាមាតា**ព្រះចាន់សីហនុ** ហើយក៏ជាព្រះមាតាសិល្បៈជាល្ខោនព្រះរាជទ្រព្យនឹងល្ខោក្បាច់បុរាណ សូម្បីតែសិល្បៈប្រពៃណី សិល្បៈ

ប្រជាប្រិយដែលចេញមកពីមហាជន ទើបក៏បានជួយលើកស្ទួយអោយមានការស្រាវជ្រាវឡើង កាន់តែរីកចម្រើនទៅមុខខ្លាំងក្លាឡើងទូរទាំងប្រទេសកម្ពុជា។

មកដល់ឆ្នាំ១៩៧០ដល់១៩៧៩សិល្បៈល្ខោនមានភាពដុនដាបយ៉ាងខ្លាំងដោយគ្រូចាស់ៗនៅសន់បន្តិចបន្តួចណាស់នៅក្នុងសម័យនោះទោះបីជាយ៉ាងណា នៅតាមបណ្ដាខេត្តនានា ខិតខំជ្រោមជ្រែងឡើងវិញដោយខិតខំស្វែងរកគ្រូចាស់ៗដែលធ្លាប់ចេញចាំក្បាច់រាំ ទាំងនោះអោយបង្រៀនឡើងវិញ។ក្រោយមកឆ្នាំ១៩៩៣ប្រទេសកម្ពុជាបានប្រែឈ្មោះថាព្រះរាជាណាចក្រកម្ពុជា ពេលនោះគេនិយមល្ខោនក្បាច់បុរាណណាស់។

ក្នុងចំណោមសិល្បៈល្ខោនក្បាច់បុរាណទាំងអស់ ខ្ញុំសូមលើកយកតែសិល្បៈល្ខោនក្បាច់បុរាណមួយចំនួន យកមកសិក្សាតែប៉ុណ្ណោះ។

# ជំពូក៣ ទម្រង់សិល្បៈរបាំខ្មែរបុរាណ

## ១.ល្ខោនស្រមោលស្បែកធំ

ល្ខោនស្រមោលស្បែកធំនេះគឺជាការរាំដើតស្បែក ឬរាំដើរកាន់ស្បែកដែលមានរូបមនុស្ស សត្វ យក្សនោះអោយមានព្រលឹង មានជីវិតរស់រវើកដូចសភាពតួរអង្គនោះពិតៗទៅតាមចង្វាក់ភ្លេងនឹងតាមពាក្យពោលរបស់អ្នកដែលជាគ្រូ ឬអ្នកដែលមានសំឡេងពីរោះក្នុងវង់សិល្បៈស្បែកនោះ។ អ្នកដើតជាអ្នកមានភារៈដើរលើកស្បែករាំជុំវិញផ្ទាំងសំពត់សយ៉ាងធំ ដែលគេអោយឆ្លុះដោយបញ្ចាំងភ្លើង ឬដោយភ្លើងចេញលលាដ៏ដូង ឬគំនរឧស ដែលគេដុតវាឆេះសន្ធោសន្ធៅ នៅលើថ្មើពីក្រោយផ្ទាំសំពត់សនោះដើម្បីអោយឆ្លុះពីលើស្បែកនោះអោយមានសភាពរស់រវើក ហាក់ដូចជាមានព្រលឹង មានជីវិតដូចមនុស្សមែនទែន ចេះនិយាយ ចេះទួញសោកជាដើម។ ប៉ុន្តែស្បែកដែលសម្តែងបានល្អមិនអាស្រ័យទៅលើតែអ្នកដើកតែម៉្យាងនោះទេ គឺត្រូវបូករួមជាមួយអ្នកគូរ នឹងអ្នកដាប់ទើបច្នៃអោយស្បែកគោមួយផ្ទាំងដែលមិនមានប្រយោជន៍អោយមានប្រយោជន៍ មានសោភណ័ភាពស្អាត និងមានជីវិតបាន។ សិល្បៈនៅក្នុងសង្គមខ្មែរ គេចាត់ទុកទម្រង់សិល្បៈស្រមោលស្បែកធំ ជាសិល្បៈសក្ការដ៏ខ្ពង់ខ្ពស់បំផុត សម្រាប់ប្រទេសជាតិទាំងមូល ព្រោះថារឿងដែលគេសម្តែងនោះគឺសុទ្ធតែស្រង់ពីអន្លើខ្លះៗ របស់ទេវកថាដ៏ល្បីល្បាញរបស់ព្រហ្មញ្ញសាសនា គឺខ្មែរយើងសម្តែងតែ**រឿងរាមកេរ្តិ៍**មួយប៉ុណ្ណោះ ដោយ

លើកឡើងបង្ហាញពីមហិទ្ធិរបស់ព្រះរាមដែលជាអវតាររបស់ **ព្រះវិស្ណុ** ឬ**ព្រះនរាយណ៍**។ ល្ខោនសក្ការនេះចប្ចុប្បន្នមិនសូវមានគេនិយម ប៉ុន្មានទេ ក្រៅពីពិធីបូជាព្រះសពព្រះមហាក្សត្រ ប៉ុន្តែអ្នកសៀមរាប គេនៅតែនិយមសម្តែងមិនសូវលោះប៉ុន្មានទេ ជាពិសេសក្នុងពិធី បូជាព្រះសព លើកសពព្រះគ្រូចៅអធិការ ឬសពមាតាបិតា ពេលខ្លះ គេសម្តែងដើម្បីសុំទឹកភ្លៀងនៅពេលដែលជួបគ្រោះរាំងស្ងួត។

ស្បែកធំដែលបានបន្សល់ទុកមកដល់សព្វថ្ងៃ មានប្រហែល តែ១០០ស្បែក តែប៉ុណ្ណោះប៉ុន្តែក្នុងចំណោមស្បែកធំទាំងអស់នោះ ថ្វីត្បិតតែគេសម្តែងរឿងរាមកេរ្តិ៍មែន តែគេមិនសម្តែងអោយចប់ គ្រប់ជ្រុងជ្រោយនោះទេ ភាគច្រើនគេសម្តែងតែអន្លើខ្លះៗ នៃចម្បាំង របស់ **ឥន្ទ្រជិត** ដែលជាកូនរបស់ **ក្រុងរាពណ៍** ជាមួយ **ព្រះលក្ស ណ៍**។ អន្លើទាំងនេះគេចែកការសម្តែងចេញជាឈុតតូចទៅតាមឈ្មោះ សរទាំងបីគឺ៖

⁕ ឈុត**សរនាគបាស** ជាសរមួយរបស់ **ឥន្ទ្រជិត** ថ្លែងក្លាយា ទៅបង្កើរបាននាគជាច្រើន ឆ្ពោះតម្រង់ទៅ **ព្រះស្រីលក្សណ៍អនុជា** និងពលរេហ៍ទាំងអស់របួសគ្រប់គ្នាដោយនាគរុំពេញខ្លួន(រូបលេខ១)

តែបានព្រះរាមថ្លែងសរទៅកាន់ក្រុងសម្ពិលិត្រុឌ ជាព្រះធម្មបិតាអោយមកជួយបង្កាត់សរចេញ(រូបលេខ២)។[៥]





✵ ឈុតសរព្រហ្មាស្រ្ត គឺជាសររបស់**ឥន្ទ្រជិត**ដែលថ្លែងទៅត្រូវ**ព្រះស្រីលក្សណ៍** ហើយក្លាយជាដើមឈើដុះបែកមែកសាខា។ ប៉ុន្តែសរនេះត្រូវបាននង្កាត់មុនពេលព្រះអាទិត្យរះ ដោយសារការខំប្រឹងប្រែងផ្សំថ្នាំរបស់ពិភេកហោរា និងហនុមានជាអ្នកស្វះស្វែងរកថ្នាំនោះបានមកពីភ្នំនន្ទច ជាមួយទឹកម៉ូត្រគោឧសភរាជពីភ្នំមហោពាន្តយកថ្មដុសពីឋានព្រហ្ម៍ និងការឃាត់ដំណើរព្រះអាទិត្រតាមការបញ្ជាពីព្រះរាម។[៦]

---

៥ ទស្សនីភាពខ្មែរ គណៈកម្មការស្រាវជ្រាវសិល្បៈវប្បធម៌ ២០០៣

៦ ទស្សនីភាពខ្មែរ គណៈកម្មការស្រាវជ្រាវសិល្បៈវប្បធម៌ ២០០៣

❋ ឈុត**សរពាន់** ជាសររបស់**ព្រះលក្សណ៍**ដែលថ្លែងចេញទៅ ហើយកើតជាព្រួញរាប់ពាន់ ទៅដោតចាក់ពេញខ្លួន**ឥន្ទ្រជិត**ធ្វើអោយ**ឥន្ទ្រជិត**ចុកចាប់ក្រៃលេង(រូបលេខ១៣)។ **ឥន្ទ្រជិត**ដកសរនោះចេញសល់ទាំងអស់នៅសល់តែសរមួយដកមិនបានសោះ **ឥន្ទ្រជិត**ក៏ហោះទៅសុំទឹកនោះនាង**មណ្ឌោគីរី**ជាមាតាបៅបង្កាត់សរនោះបានដូចក្តីប្រាថ្នា(រូបលេខ១៤)។


រូបលេខ១៣


រូបលេខ១៤

នៅទីបំផុត **ឥន្ទ្រជិត** ស្លាប់ក្រោមស្នាព្រះហស្តរបស់**ព្រះរាម** គឺដោយការថ្លែងសរ **ព្រាហ្មស្រ្ត** ផ្តាច់សិរសា **ឥន្ទ្រជិត** ហើយក្បាលនោះត្រូវអង្គទប្រដាក់លើតោកដែលខ្ចីមកពីឋានព្រហ្ម នឹងថ្លែងសរប

ញូនទៅស្ថានតុសិតនៅទីបញ្ចប់នៃសង្គ្រាម។[៧] យើងប្រាកដជាយល់យក្សតំណាងអោយសភាវអាក្រក់ ឯព្រះរាមតំណាងអោយសភាវល្អ ដូច្នេះព្រះរាម បានកំចាត់ក្រុងរាពណ៍អោយវិនាសពីផែនដីទៅទើបព្រះអង្គ អាចនៅជុំប្រះញាតិព្រះអង្គប្រកបដោយសុភមង្គលបាន ដោយន័យថាកំចាត់សភាអាក្រក់ចេញពីភពផែនដីនេះហើយបាន ជាពីសម័យមុនៗ គេសម្តែងរបាំក្បាច់បុរាណនេះនៅពេលឆ្លងសង្ក្រាន(ចូលឆ្នាំថ្មី) ដើម្បីកំចាត់បង់នូវរាល់ឧបទ្រព្យចង្រៃ ឧត្បាតកាឡកិណី ទាំងឡាយអោយជៀសចេញពីព្រះនគរ គឺគេសម្តែងនៅក្នុងព្រះបរមរាជវាំងតែប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្ន ការសម្តែងបែបនេះលែងមានទៀតហើយក្នុងព្រះបរមរាជវាំងគេជំនួសដោយពិធីភាណយក្សវិញម្តង។ ចំណែកឯវង់ភ្លេងសម្រាប់ប្រគុំនៅពេលសម្តែងស្បែកធំនេះវិញគឺភ្លេងពិណពាទ្យទាំងវង់តូចនឹងវង់ធំ។

- ❋ វង់តូច

–រនាតឯក

–សម្ភោ

–ស្រឡៃ

---

៧ ទស្សនីភាពខ្មែរ គណៈកម្មការស្រាវជ្រាវសិល្បៈវប្បធម៌ ២០០៣

-ស្គរធំមួយគូរ

-គងវង់ធំ

❋ បើវង់ធំមានច្រើនឧបករណ៍ច្រើនលើសពីវង់តូចនេះ ដូចជា

-រនាតធុង

-រនាតថោង

-រនាតដែក

-គងវង់តូច

-ស្រឡៃតូច

-ស្រឡៃធំ

-ឈឹង

សូមបញ្ជាក់ដែលថាបើតាមប្រសាស៍របស់លោកព្រឹទ្ធាចារ្យ **ពេជ្រ ជុំត្រាវិល** បានលើកឡើងថាចម្បាំងឥន្ទ្រជិតទាំងបីឈុតនេះ គឺគេសម្តែងក្នុងរយះពេល ៧យប់៧ថ្ងៃបានចប់ បើត្រឹមសង្ខេបត្រឹម៣យប់៣ថ្ងៃ បើខ្លីបំផុតគឺត្រឹមតែ១៧នាទីទៅ២០នាទីតែប៉ុណ្ណោះ។

ចំពោះបទភ្លេងវិញក្នុងអន្លើចម្បាំង ឥន្ទ្រដូចបានរៀបរាប់ខាងលើ នេះមានប្រមាន២០បទ ហើយបទនីមួយៗហាក់គួរបញ្ជាក់នូវដំណើរមួយ ឬមនោសញ្ចេតនាមួយយ៉ាងច្បាស់លាស់ទៅតាមក្រុមតួអង្គផ្សេងៗសម្គាល់ដាច់ស្រឡះពីគ្នាពុំលាយឡំឡើយ ដូចជាពេលមានជ័យជម្នះ សោយសោក សប្បាយ តាំងសីលជាដើម។

⎈ មានបទដូចជា៖

| | |
|---|---|
| -សាធុការ | សម្រាប់ពិធីហោមរោង |
| -ដើត | ដំណើរច្បាំងឬហោះ |
| -ដើតឃឹង | ថ្លែងសរ |
| -ដើតចាប់ | ច្បាំងនឹងស្វាប្រចាប់ |
| -ដំណើរក្នុង | កងទ័ពយក្ស |
| -បទផ្លិក | ដំណើរគ្រុឌ |
| -លោ | អន្លើបុញ្ញកាយអណ្តែតទឹក |
| -ដំណើរក្រៅ | ដំណើរកងទ័ពមនុស្ស |
| -ត្រាក់ | ប្រែក្រឡា |
| -រោទ៍មួយជាន់ | ដំណើរចូលទៅច្បាំង |
| -អ្នកតូចអ្នកធំ | ដំណើរកំសត់យំសោក |
| -នាងលោត | ដំណើរកំប្លុកកំប្លែង |
| -ក្លុំ | ពិធីតាំងសីល |

## ក.វិធីធ្វើភាពស្បែក

ការលេងមហោស្រពពីចម្បាំកងទ័ពដោយប្រើរូបស្បែកដែលឆ្លាក់ជារូប តាមដំណើរសាច់រឿងគេហៅថាភាពស្បែក។ឯវិធីធ្វើភាពស្បែកនោះវិញ មុនដំបូងគេយកស្បែកគោទៅត្រាំទឹកអោយទន់រួចយកទៅហាលថ្ងៃអោយស្ងួត ហើយយកដែកដែលមានមុខមុតមកកោសអោយស្តើង នឹងអោយមានផ្ទៃរាបស្មើ ទើបគេយកទឹកខ្មៅមកលាបលើស្បែកនោះអោយសព្វទាំងសងខាងប្រមាណអោយមើលទៅឃើញខ្មៅល្អ រួចហើយទើបយកទៅហាលថ្ងៃម្តងទៀតអោយស្ងួត លុះស្ងួតហើយទើបយកទៅខាត់អោយរលោងល្អ។ ប្រសិនបើមិនចេះគូរដោយខ្លួនឯងទេ ត្រូវរកនរណាម្នាក់ដែលប៉ិនប្រសប់គូរ ហើយត្រូវប្រកបដោយភាពរស់រវើកតាមសាច់រឿង។ ពេលគូររូបហើយ ត្រូវមើលអោយសព្វគ្រប់ បើឃើញថានៅទាស់ចិត្តកន្លែងណា ត្រូវថែមថយកន្លែងណាថែមទៀត ហើយទើបដាប់កន្លែងនោះបន្ថែម ដោយដែកឆ្លាក់មានមុខងារ នឹងសណ្ឋានផ្សេងៗគ្នា មានដែកពន្លាក ដែកក្រចកដើម ។ ពេលដាប់រួចរាល់ហើយគេត្រូវយកបញ្ចាំងថ្ងៃមើលសិន បើមើលទៅមិនសូវសមកន្លែងណាឬខ្វះអ្វីទៀតដើម្បីអោយស្បែកមានសម្រស់កាន់តែស្រស់ស្អាតជាងមុន បើគេឆ្លាក់បានច្រើនផ្ទាំងល្មមលេងបានហើយគេទើបជ្រលក់ ឬកោស អោយមានពណ៌ផ្សេងៗតាមដែលត្រូវការ។ គេអាចលុបកោសល្បប់ខ្មៅចេញអោយអស់ ហើយក៏ទៅជាពណ៌ស បើបើចង់អោយអ្វីត្រូវមានវិធីសម្រាប់បង្កើតពណ៌ស្បែកនោះតាមទម្រង់នៃសិល្បៈ។ ពេលរួចរាល់អស់ហើយទើបគេយកចំរៀកឬស្សីបួនចំ

រៀកមកកៀបសងខាងធ្វើមេសម្រាប់កាន់ដើរទៅមកនៅពេលស ម្តែង រាល់ៗរូបស្បែកទាំងនោះ ប៉ុន្តែស្បែកធំគេមិនប្រើពណ៌ដទៃក្រៅពីពណ៌ខ្មៅទេ ក្រៅពីនោះគេអាចប្រើពណ៌បាន។ អ្វីដែលសំខាន់បំផុតនោះគេធ្វើយ៉ាងអោយស្បែកនោះមានព្រលឹង មានន័យថាស្បែកដែលត្រូវយកទៅជើតនោះត្រូវតែរស់រវើកជានិច្ច ឯព្រលឹងរបស់ស្បែកមិនស្ថិតនៅតែលើអ្នកតែម្នាក់នោះទេគឺ រួមទាំងអ្នកដាប់អ្នកគូរ ដូចស្គាល់ពីស្ថានភាពរបស់តួរអង្គ ស្ថិតក្នុងសភាពយ៉ាង អ្នកពោល និងអ្នកជើតត្រូវតែស្គាល់ចង្វាក់ភ្លេងនឹងបរិយាកាសរបស់បទនីមួយ ។

# ១.វីធីធ្វើឆាកផ្ទុះ

## ❋ ឆាកផ្ទុះសម័យមុន

ឆាកសម្រាប់ឆ្លុះភាពស្បែកនោះ គេច្រើនធ្វើដោយសំពត់សស្តើង ហើយសំពត់បែបនោះមកកាត់ដើរភ្ជោះគ្នាចងអោយតូចឬធំគប្បីធ្វើទៅតាមតម្រូវការធ្វើជាផ្ទៃត្រង់ កណ្តាលដើម្បីនិងអោយឆ្លុះពន្លឺឃើញស្បែកនោះច្បាស់។ នៅជាយជុំវិញគេធ្វើដោយសំពត់ផាឱបយ៉ាងក្រាស់ដើម្បី បំបាំងភាពស្បែកនោះក្នុងវេលាចេញលេង រីមជាយវិញគេដាក់ខ្សែជាច្រើនអន្លើតាមជាយនោះសម្រាប់ចងត្រដាងឆាកឆ្លុះនេះបួនជ្រុងស្មើប្រវែងទំហំពក៏មាន១១ហត្ថមានស្រេចទៅតាមតម្រូវការ(រូបលេខ៥)។ ចំណែកពន្លឺសម្រាប់ឆ្លុះអោយឃើញស្បែកវិញគេប្រើ

លលាដ៍ដូង គឺគេយកមកគរពីក្រោយផ្ទាំងសំពត់ និងមានកន្ទេលព័ទ្ធជុំវិញការពារខ្យល់។ ប្រសិនបើភ្លើងនេះមិនល្អទេ ស្បែកក៏មិនសូវលេចរូបរាងច្បាស់ ហើយក៏មិនសូវល្អមើលឡើយដែរ។



រូបលេខ៥

* ឆាកស្លុះសម័យទំនើប

នៅក្នុងសម័យសាកលភាវូបនីយកម្មការសម្តែងសិល្បៈគ្រប់ទម្រង់មានការងាយស្រួលបំផុត ស្បែកធំដែលធ្លាក់ប្រើលលាដ៍ដូងសម្រាប់ដុតធ្វើអោយស្បែកស្លុះប៉ុន្តែបច្ចុប្បន្នគេប្រើភ្លើងហ្វាធំៗ តែមួយឬពីរមកបញ្ចាំងជាការស្រេចមិនបាចភ័យខ្លាចរលត់ភ្លើងស្លុះនោះទេ(រូបលេខ៦)។



រូបលេខ៦៖ ការសម្តែងធំនៅក្នុងមហោស្រព

គ.ការ[illegible]ស្បែក

## ❋ សម័យមុន

បើតាមប្រសាសន៍ចាស់ព្រឹទ្ធាចារ្យនៅតំបន់សៀមរាបវិញ តាៗចាស់ៗជាសិល្បៈករ ជើតស្បែកគាត់បានលើកឡើងថា៖ ពេលទៅជើតស្បែកម្តង គេតែងសម្តែងនៅវាលស្រែ ឬនៅក្នុងវត្តដោយប្រើបង្គោលពីរសំរាប់ចងផ្ទាំងសំពត់ដែលចងដាំជាប់នឹងដី ហើយឬស្សីចងជាមេទទឹងលើក្រោម ដើម្បីអោយលាតសំពត់តឹងណែន ងាយនឹងឆ្លុះស្បែកពីក្រោយផ្ទាំងសំពត់នោះ ។ ពីខាងក្រោយសំពត់គឺផ្ទើរដាក់លលា ដូងសំរាប់ដុតភ្លើងនៅជុំវិញផ្ទើរភ្លើងនោះគេព័ន្ធដោយកន្ទេលស្លឹកត្នោតដូចដែរបានរៀបរាប់ខាងលើស្រាប់ ។អ្នកពោលនិងក្រុមភ្លេងនៅខាងមុខកន្លែងជើតស្បែក អ្នកទស្សនាក៏អង្គុយនៅទីនោះដែរ ប៉ុន្តែទុកប្រវែងអោយឆ្ងាយល្មមនិងអ្នកជើតគេសម្តែងបាន។

*❋សម័យទំនើប

សម័យបច្ចុប្បន្នកន្លែងសម្រាប់សម្ដែងសិល្បៈផ្សេងៗមានល្ខោនស្បែកធំ ស្បែកតូច និងទម្រង់ដទៃទៀត គេនិយមសម្ដែងនៅរោងមហោស្រព ដែលប្រកបដោយបច្ចេកវិទ្យាទំនើបផ្សេងៗមានឧបករណ៍បំពងសំឡេង ភ្លើងបំភ្លឺមហោស្រពទាំងមូល ។*

## ឃ.វិធីលេងភាពស្បែក

*ភាពស្បែកនេះគេលេងតែពេលយប់ប៉ុណ្ណោះ ព្រោះត្រូវការពន្លឺភ្លើង សម្រាប់ឆ្លុះអោយឃើញរូបស្បែក។ មុនពេលសម្ដែងគេត្រូវយកគ្រឿងភ្លេងទៅដាក់ក្នុងរោងអោយហើយស្រេចក្នុងវេលាថ្ងៃ លុះដល់វេលាព្រលប់អ្នកក្រុមភាពស្បែកទាំងប៉ុន្មានត្រូវមកជួបជុំគ្នានៅក្នុងរោង ឬក៏នៅខាងមុខឆាកសម្ដែងដោយមានរូប* **ព្រះមុនីឥសី ព្រះថ្ងៃជ័ព្រះឯរាយណ៍និងព្រះថ្ងៃជ័ព្រះឥស្វរ** *ស្លាធម៌បាយសី ទាំងរណ្ដាប់ផ្សេងៗ(រូបលេខ៧-៨) មុននិងចាប់ផ្ដើមខណៈនោះម្ចាស់បុណ្យឬអ្នកដែលជួលមកសម្ដែងគេងត្រូវយកទៀន៣ដើម ប្រាក់៣ស្លឹងជារបស់កំណាល់គ្រូទៅ ម្ចាស់ភាពស្បែក ម្ចាស់ភាពស្បែកយកទៀន១ដើមទៅបិទជាប់នឹងសម្ភោ ទើបបទសារធុការបន្លឺឡើងពិធីហោមរោងក៏ចាប់ផ្ដើមដោយបទសាធុការនេ ហើយអ្នកពោលទើបយកទៀនអុជបូជានៅស្បែកស្ដេចពីរអង្គគឺរូប* **ព្រះឥស្វរ** *និង* **ព្រះឯរាយណ៍** *ឯមនុស្សផ្សេងៗទៀតនាំគ្នាស្រែកហ៊ោឡើង៣ដង។*

អ្នកដើតក៏លើករូបព្រះមុនីឥសីមកឡើងដើត ភ្លេងក៏បន្លឺ បទដើតឡើង ទៅតាមលំដាប់ ។




រូបលេខ៧-៨៖ព្រះនារាយណ៍ និងព្រះឥសូរ

ពេលអុជទៀនបូជាហើយថយឈរតាមកន្លែងរបស់ខ្លួនវិញហើយ ទើបចាប់ប្រារព្ធបទនមស្សការព្រះរតនត្រ័យ លុះពេលចប់គេបន្លឺភ្លេង ៣បទ តាមទំនៀមដោយចប់មួយបទភ្លេង ដើតម្ដងគ្រប់វារៈ៣ដង។ បន្ទាប់មកអ្នករក្សាចន្លុះ យកចន្លុះ៣ដើមមកអុជជុំវិញជើងចន្លុះ៣ជុំហើយភ្លើងចន្លុះនោះទៅអុជនៅអាចម៍ចន្លុះនៅផ្ទើរដែលមានលលាដ៍ដូងនៅទីនោះស្រាប់ ពេលភ្លើងឆេះឡើងពិពាទ្យបន្លឺក្នុងខណៈពេលនោះព្រមគ្នាតែម្ដង ចំណែកអ្នកពោលក៏ចេញមកពន្លត់ទៀនហើយក៏សូត្រអាគមគាថាតាមដែលខ្លួនធ្លាប់ប៉ុណ្ណោះឈ្មោះថាចប់ពិធីហោមរោង ឬហ៊ុមរោងបើកមុខព្រះ ។

លុះហ៊ុមរោង ឬហោមរោងចប់ហើយលំដាប់នោះគេចាប់លេងរឿងស្វាប្រចាប់គ្នា គឺស្វាស នឹង ស្វាខ្មៅដែលដើកតពីខាងឆ្វេងនឹងខាងស្ដាំ មកប្រចាប់គ្នាត្រង់កណ្ដាលឆាក វេលានោះអ្នកភ្លេង

លេងភ្លេងដើតតែត្រូវផ្ដុំតែស្រទៀតៃ១ និងស្គរ ចំណែកឧបករណ៍ក្រៅពីនោះត្រូវបង្អន់សិន ហើយត្រូវវាយបទដើតលាត ស្វាទាំងពីរនោះចាប់ប្រចាប់គ្នា លេងគ្នាទៅវិញទៅមក ធ្វើយ៉ាងនេះគ្រប់៣ជុំ ទើបគេដើតរូបព្រះមុនីឥសីឡើង ទន្ទឹមនឹងនេះស្វាសបចាប់បានស្វាខ្មៅហើយនាំយកទៅអោយលោកតាមុនីឥសី ព្រះមុនីឥសីក៏សុំអោយលែងស្វាស លែងស្វាខ្មៅ ទើបដើតត្រឡប់ចូលក្នុងវិញ(រូបលេខ៩-១១)។



រូបលេខ៩៖ស្វាប្រចាប់



រូបលេខ១០៖ស្វាប្រចាប់



រូបលេខ៩៖ឥសីអោយស្វាស ប្រលែងស្វាខ្មៅ

ដូនកាលមុនគេលេងរឿងស្វាប្រចាប់គ្នាទេ តែគេលេងរឿងមណីមេខលា(រូបលេខ១២)។ កាលបើចប់ពិធីហោមរោងនឹងរបាំបើករោងសម្រេចដូច្នេះហើយ គេចាប់ផ្ដើមលេងរឿងទៅតាមសាច់រឿងដែលបានលគ្រោងទុកសម្រាប់សម្ដែង។ ស្បែកដែលឆ្លាក់ជារូបហើយមានបញ្ញត្តិឈ្មោះផ្សេងៗ ដូចជា រូបដើម មិនថាមនុស្ស យក្ស គេហៅថាភាពបទចរទាំងអស់។ ភាពដែលជារូបហោះហើរ មិនថាមនុស្សយក្ស ឬស្វាហៅថាភាពហោះទាំងអស់។ ភាពដែលផ្ទុំពេលហៃរស្ដេចលើកទ័ពចេញទៅ ទៅច្បាំងមិនថាមនុស្ស យក្ស ឬស្វាហៅថាភាពរេហាពល៍។[៨] ឯអ្នកសម្ដែងវិញគឺអាចលើកស្បែកដើតជុំវិញផ្ទាំងសំពត់ហើយសម្លេកបំពាក់គេមិនស្លៀកតម្រូវតាមតួអង្គស្បែកនោះទេ គេច្រើនស្លៀកក្បិនក្រណាត់ធម្មតា និងអាវទ្បេវវ៉ះ។

---

៨ ទស្សនាវដ្ដីកម្ពុជសុរិយាលេខ៣ ១៩៤៨



*រូបលេខ១២៖*
*របាំមណីមេខល្លា*

**ឃ. ស្បែកស្តេច**

*ពាក្យថាស្បែកស្តេចមានន័យថា ស្បែកជាប្រធានលើស្បែកទាំងអស់ សំខាន់ជាងស្បែកដ៏ទៃទៀត ហើយខ្វះមិនបានដាច់ខាតនៅពេលសម្តែង និងពេលចាប់ផ្តើមដាប់ស្បែ។ ស្បែកស្តេចជារូបរបស់តួអង្គបីដែលសំខាន់ៗ ជាប្រធានជាធំលើរូបទាំងឡាយ ក៏ជារូបសំខាន់ក្នុងរឿង គឺ***ព្រះឥសូរ ព្រះនរាយណ៍** *នឹង***ព្រះមុនីឥសី***ដែលជាស្តេចស្បែក។ ព្រោះថាស្បែកស្តេចនេះទំរាំតែបានជាស្តេចស្បែកត្រូវឆ្លងកាត់តំណាមច្រើនណាស់ ដើម្បីធ្វើស្តេចស្បែកនេះមានភាពលំបាកច្រើនណាស់ គេត្រូវយកស្បែកគោងាប់ដោយខ្មោចព្រាយធ្វើឬងាប់តែសាកមកធ្វើរូប***ព្រះឥសូរ***និងរូប***ព្រះនរាយណ៍***តែឥសីគេយកស្បែកធំ ឬខ្លាឃ្មុំមកធ្វើ បើមិនបានស្បែកទាំងពីរនេះទេ គេជឿថាមិនរូបហ្នឹងមិនពូកែសក្តិសិទ្ធិឡើយ។ចំពោះរយៈពេលធ្វើវិញ គេ*

ត្រូវតែលៃលកយ៉ាងណាក្នុងរូប១អង្គ ទាំងគូរ ទាំងដាប់ ត្រូវតែអោយហើយក្នុងរយៈពេលមួយរាត្រី កុំអោយរំលងដល់ពេលអរុណរះថ្ងៃថ្មីឡើយ។ ចំណែកការចាប់គូរ ដប់រូបនេះគេត្រូវរៀបព្រះពិស្ណុកា រឭកដល់ព្រះមុនីឥសី ពេលដែលគូរ ដាប់ អ្នកទាំងនោះត្រូវស្លៀកពាក់សពានាទាំងអស់ ។

## ង.របស់បូជាស្តេចស្បែក

កាលនឹងធ្វើរូបទាំងបីនេះ គេត្រូវរៀបរបស់ដង្វាយសម្រាប់គ្រូតាមទំនៀមគឺមានបាយសីប៉ាក់ឆាម១គូក្រយាបួស(ក្រយាបួសម្ហូបចំណី ដែលមិនរលាយដោយគ្រឿងចំអាប)ត្រីសាច់១សំរាប់ ក្បាលជ្រូកមួយ មាន់ស្ងោរមួយ និងជមបួន(រូបលេខ១៣)។



រូបលេខ១៣៖
រណ្តាប់វិស្ណុការ

ណាផ្សេងៗគ្នា។ **ព្រះឥសូរ** ខ្សែវហើយគូរជាក្បាច់រចនាតាមគ្រឿងសំលៀកបំពាក់អោយវិចិត្រជាងរូបទាំងពួង។

## ២.ល្ខោនស្បែកពណ៌

សិល្បៈស្បែកពណ៌ជាសិល្បៈស្បែកគោ តែមិនមែនជាសិល្បៈស្រមោលដូចជាស្បែកធំនិងស្បែកតូចទេព្រោះជារូបចំលាក់ដែលលាបពណ៌ ដូចគំនូរលាន ដូចពណ៌បុរាណរបស់ខ្មែរ ហើយសម្រាប់សម្តែងតែពេលថ្ងៃប៉ុណ្ណោះ(រូបលេខ១៤-១៥)។ ចំណែកឯកាជើតវិញគឺជើតនៅខាងមុខដោយប្រើសំពត់ដែលមានពណ៌ខ្មៅ និងមានពណ៌ស្រគាំដើម្បីអោយឆ្លុះស្បែក និងឃើញកាន់តែច្បាស់អោយនូវរូបគេលាបពណ៌ មកនិទានជារឿងផ្សំជាមួយការសម្តែងរបស់សិល្បករ។ ល្ខោនស្បែកត្រូវបានបង្កើតឡើងក្នុងសម័យចតុមុខរវាងឆ្នាំ**១៨៥៩** ដល់**១៩០៤** ដោយការយកព្រះរាជហ្ឫទ័យទុកដាក់ពីព្រះមហាក្សត្រី**ស៊ីសុវត្ថិ កុសុមៈនារីរ័ត្ន**។ ភាពខុសគ្នារបស់ពណ៌ស្បែក ត្រូវបានលាបទៅលើស្បែកនោះតាមបែបបទទ្រង់ទ្រាយរបស់តួអង្គ ហើយស្បែកនេះក៏ជាស្បែកដែលនៅនឹងថ្កល់គ្មានចលនាដូចស្បែកធំដែរ។ សិល្បៈល្ខោនស្បែកពណ៌នេះត្រូវបានបាត់បង់អាក់ខានលេងសម្តែងជាយូរឆ្នាំមកហើយប្រហែលតាំងពីឆ្នាំ**១៩៣០**ឬ**១៩៤០**មកម្ល៉េះ ។បើតាមពត៌មានដែលប្រមូលបាន នៅឆ្នាំ**១៩៧៩**គេឃើញមានសល់តែ២០ផ្ទាំងតែប៉ុណ្ណោះនៅព្រះបរមរាជវាំង។ បើយើងពិនិត្យមើលអោយម៉ត់ចត់ទៅស្បែកទាំងនោះគឺជាស្នាដៃរបស់សិល្បករជំនាញៗក្នុងរោងជាងនៃព្រះរាជាវាំង ហើយស្បែកទាំងអស់ដែលសេសសល់គេអាចសម្តែងរឿងរាមកេរ្តិ៍ឥណ្ឌា បុស្បា នឹងរឿងដ៏ទៃទៀត។មកដល់ឆ្នាំ**២០០០**ទើបមានសៀវភៅបោះពុម្ភពីល្ខោនស្បែកពណ៌ បន្ទាប់មកទើបខរៀបចំមហោស្រពនៅចតុមុខ ក្រោមជំនួយពីអង្គការសហ

រដ្ឋអាមេរិច ដោយលោកបណ្ឌិត **សំរេជ** ដែលជា គណៈកម្មាស្រាវជ្រាវសិល្បៈរបស់ក្រសួងវិចិត្រសិល្បៈបានយករឿងកូរសមុទ្ទទឹកដោះមកសម្ដែងនាពេលនោះ។



រូបលេខ៖១៥



រូបលេខ៖១៤

## ក. ស្បែកស្តេច

រូបដែលជាស្បែកស្តេច នៅក្នុងទម្រង់សិល្បៈស្បែកពណ៌នេះ មិនខុសគ្នាអ្វីពីរូបស្តេចស្បែកក្នុងពីទម្រង់សិល្បៈល្ខោនស្រមោលស្បែកធំឡើយ ព្រោះវាស្ថិតនៅក្នុងទម្រង់ចាមួយគ្នា ដូច្នេះស្បែកស្តេចក៏ជាមួយគ្នាដែរ គ្រាន់តែមួយរូបលាបពណ៌ ហើយមានទំហំតូចបន្តិចប៉ុណ្ណោះ។ ស្បែកតូចនេះពេលដាប់ ពេលគួរគេត្រូវរឭកដល់ព្រះមុនីឥសីជាមុនសិន។

## ខ.រណ្តាប់បូជាគ្រូ

*ដូចជារណ្តាប់បូជាគ្រូរបស់ស្បែកធំដែរ។*

## គ. វិធីលេងស្បែកពណ៌

*វិធីលេងស្បែកពណ៌គេតែងសម្តែងនៅពេលថ្ងៃ ហើយខុសគ្នាខ្លះៗពីការសម្តែងល្ខោនស្រមោលស្បែកធំដែលអ្នកដើត ដើតរូបដើរជុំវិញផ្ទាំងសពត់បាន ឬស្បែកតូចដែលអ្នកអង្គុយដើតពីក្រោយផ្ទាំងសំពត់ស ដោយពឹងលើពន្លឺភ្លើងឆ្លុះយកស្រមោលពីខាងក្រោយ។ ចំណែកខាងការសម្តែងស្បែកពណ៌វិញ យើងសង្កេតឃើញមានលក្ខណៈពាក់កណ្តាលជាការសម្តែងល្ខោន នឹងពាក់កណ្តាលជាសម្តែងស្បែក ពោលគឺអ្នកដើតមានប្រុស មានស្លិតស្រីក្នុងសម្លៀកបំពាក់នឹងគ្រឿងអលង្ការស្អាតៗតាមតួអង្គរូបស្បែក រួចគេដើតស្បែកមកខាងមុខផ្ទាំងសពត់ខ្មៅ ឬស្រគាំពេលខ្លះគេបញ្ឈរស្បែកនឹងផ្ទាំងក្រណាត់ រួចគេសម្តែងជាល្ខោនដោយមាននិយាយរៀបរាប់ជជែកពិភាក្សា ឬឆ្លើយឆ្លងស្នេហាគ្នា លាយទ្បំដោយភ្លេងថែមទៀតផង រួចទើបចាប់ស្បែករបស់គេដើតជាបន្តទៀត។*

### ឃ. គ្រឿងភ្លេង

-រនាតរ

-គងវង់ធំ

-ស្រឡៃតូច

-សម្ភោ

-ស្គរធំ

ឯបទភ្លេងជាច្រើនតែខ្មីពីមហោរី។

## ៣. ល្ខោនស្រមោលស្បែកតូច ឬ អាយ៉ង

ស្បែកតូច ឬអាយ៉ង ជាប្រភេទសិល្បៈដែលស្ថិតនៅក្នុងក្រុមល្ខោនស្រមោលដូចស្បែកធំដែរហើយជាចម្លាក់ដែលឆ្លាក់នៅលើស្បែកគោដែលមានទំហំតូចៗ ហើយមិនមែនជាចម្លាក់នឹងថ្កល់ ដូចសិល្បៈស្បែកធំ ស្បែកលាបពណ៌ឡើយ។ផ្ទុយទៅវិញទម្រង់សិល្បៈនេះជាចម្លាក់ ដែលអាចមានចលនាកំរើកបានដូចជាលើកដៃ លើកជើង ហាមាត់និយាយ នឹងច្រៀងបានដោយសារមានលក្ខណៈពិសេស ដូច្នេះហើយ បានគេអាចហៅថាសិល្បៈល្ខោនស្រមោលស្បែកតូចនេះថាជាអាយ៉ង(រូបលេខ១០)។ ពាក្យថាអាយ៉ងជាសិល្បៈ ម៉្យាងដែលត្រូវគេដើតឬ ញាក់ដោយនាក់ ដ៏ទៃ។ស្បែកតូច ឬអាយ៉ងនេះមានលក្ខណៈខុសពីល្ខោនស្បែកដ៏ទៃៗទៀត ព្រោះវាប្រជាប្រិយកំប្លុកកំប្លែងងាយមើលងាយយល់នឹងអាចសម្តែងរឿងបានជាច្រើន

ដូចជារឿងនិទានបុរាណ ប្រវត្តិសាស្ត្រ អប់រំដែលទាក់ទងនឹងសង្គមបច្ចុប្បន្នផង។ នៅប្រទេសកម្ពុជាមានការបញ្ញាត្តិឈ្មោះ៣មាន៖ ស្បែកតូច អាយ៉ង ណាំងតាលុង ទៅតាមការនិយមទៅតាមតំបន់នីមួយៗខុសៗគ្នា (រូបលេខ១៦-១៧)។ ផ្អែកទៅតាមការនិយមរបស់ជនជាតិខ្មែរ ដែលយល់ថាពាក្យតុក្កតានឹងពាក្យអាយ៉ងមានន័យដូចគ្នាគឺ សំគាល់លើវត្ថុឥតវិញ្ញាណទាំងឡាយទោះបីមានទំហំមាឌ ឬសំប៉ែតដូចជារូបចម្លាក់ធ្វើអំពីឈើ ធ្វើអំពីកំណាត់ញត់សំឡី រូបចម្លាក់ធ្វើអំពីដីឥដ្ឋ នឹងធ្វើអំពីស្បែកហើយសព្វថ្ងៃធ្វើអំពីក្រដាសនិងជ័រប្លាស្ទិកទៀតផង ។ វត្ថុទាំងនោះត្រូវបានដើតញាក់ឬជំរុញអោយធ្វើសកម្មភាពដោយអ្នកដទៃគឺសិល្បករអ្នកដើត។



រូបលេខ៖១៦-១៧

ចំពោះប្រភពស្បែកតូចឬអាយ៉ងនេះវិញយើងអាចជួបប្រទះនូវឯកសារជាច្រើនដែលអស់លោកអ្នកប្រាជ្ញទាំង កម្ពុជាទាំងបរទេសបាន

បន្សល់ទុកមតិខ្លះ ដោយស្មានថាស្បែកតូច ឬរអាយ៉ងនេះប្រហែលជាយោងយកកំណើតមកពី ម៉ាឡេស៊ី? ឯមតិខ្លះទៀតសន្និដ្ឋានថា អាយ៉ងខ្មែរប្រហែលមានកំណើតមកភូមិម៉ាលាយ៉ងទឹកដីភាគខាងលិច ខេត្តបាត់ដំបង ខ្លះថាប្រហែលនៅម្តុំខ្ពបតាយ៉ង គឺវត្តបុទុមវតីសព្វថ្ងៃ។ តាំងពីយូរលង់ណាស់មកហើយ ការស្រាវជ្រាវពីឈ្មោះអាយ៉ងនេះដែលជាពាក្យ សម្រាប់សម្គាល់ដល់តួអង្គតុក្កតដ៏ល្បីល្បាញរបស់ទម្រង់សិល្បៈស្បែកតូចនេះ នៅភ្នំពេញហើយប្រជាជនជាច្រើនមានការនិយមរាប់អាន។ ខ្លះថារអាយ៉ងនេះប្រហែលជាកើតនៅភូមិត្រយ៉ង ឃុំពួកស្រុកពួក ខេត្តសៀមរាប ដែលមិនឆ្ងាយពីទីក្រុងអង្គរឡើយ នៅទីនោះមានផលិត និងសម្តែងតុក្កតាតាំងពីយូរលង់ណាស់មកហើយ។ ចំណែកឯទិន្នន័យដ៏សំខាន់ ដែលទាក់ទងដើមកំណើតតុក្កតា ឬរអាយ៉ងនេះគឺការសិក្សាសិលាចារឹកខ្មែររបស់អ្នកស្រី**៣៧ សាវ រស**ដែលបានបញ្ជាក់អោយយើងដឹងថានៅក្នុង សិលាចារឹកមុនសម័យលេខK១៥៥មានចែងអំពីសិល្បការិនីសម្តែងតុក្កតា ក្នុងពិធីបូជាថ្វាយចំពោះអាទិទេពស្វរស្វតីដែលជាអាទិទេពតំណាងអោយអាទិទេពសំណួនវោហាដ៏ពិរោះ នឹងសិល្បៈ។នេះជាភស្តុតាងដែលធ្វើអោយយើងដឹងកាន់តែច្បាស់ថា ទម្រង់សិល្បៈនេះមានកំណើតតាំងពីមុនសម័យកសាងប្រាសាទអង្គរម្ល៉េះ ហើយលោកស្រីលើកពីពត៌មាន ឬឯកសារដ៏មានសារសំខាន់មួយទៀតដែលទាក់ទងនឹងសិល្បៈល្ខោនស្រមោលស្បែកតូចនៅកម្ពុជាព្រោះនៅឆ្នាំ២០០០លោក Hamza Awang Amat ជាសាស្ត្រាចារ្យជាអ្នកដឹកនាំសម្តែងសិល្បៈ

ល្ខោនស្រមោលដ៏ល្បីល្បាញរបស់ ប្រទេសម៉ាឡេស៊ីដោយលោក ទទួលបានពានរង្វាន់ជ័យលាភីសិល្បៈនឹងវប្បធម៌ Arts and culture prize របស់ the Fokuoka Asion Culture Prize 2000។នៅក្នុងអត្ថបទរបស់លោកបានបញ្ជាក់ថា ល្ខោនស្រមោលwayang kutit ខេត្តតេឡាន់តាន់ក្នុងប្រទេសម៉ាឡេស៊ីមានប្រភពមកពីប្រទេសកម្ពុជា ដោយហូរចូលទៅជ្រោយម៉ាឡេតាមប្រទេសថៃភាគខាងត្បូង[៧] ។ ចំពោះគ្រឿងឧបករណ៍ភ្លេងសម្រាប់ប្រជុំជូនស្បែកតូចទាំងអស់នោះមាន៖

-រនាតឯក

-គងវង់ធំ

-ស្រឡៃ

-ស្គរ។

ឯបទភ្លេងវិញ ខ្ចីពីបទភ្លេងមហោរីភាគច្រើន។ ចំណែកឯស្បែកតូចដែលគេសម្តែងនៅបាត់ដំបងវិញគេមិនមានប្រើវង់ភ្លេងពិណពាទ្យទេ ផ្ទុយទៅវិញសម្រាប់ប្រជុំសម្តែងស្បែកតូច ឬអោយគេច្រើនតែប្រើឧបករណ៍ដូចជា៖

-ស្គរតូចមួយ

-ស្គរដៃមួយគូ

-ស្រឡៃតូចមួយ

-គងដោះតូចមួយ(គងមង)

-ហើយមានទ្រាប់ក្រណាត់ រឺឬស្សីផង។

ចំពោះស្បែកស្តេច និងកគ្រឿងបូជាគ្រូដូចគ្នានឹងល្ខោនស្រមោលស្បែកធំព្រោះមានប្រភពតែមួយ គ្រាន់តែមួយញាក់បានហាមាត់ស្តីនិយាយបាន និងទំហំតូចជាងស្បែកប្រភេទខាងដើមប៉ុណ្ណោះ។ ពេលសម្តែងខុសត្រង់តែពេលហោម គ្មានការសម្តែងស្វាប្រចាប់ ឬមណីមេខលា។

## ៤. ល្ខោនខោលបុរាណ

ពាក្យថា ខោលឬ ល្ខោនខោលនេះបើយោងតាមសង្ឃដីការបស់សម្តេចសង្ឃ**ជួន ណាត**ដែលបានកត់ត្រាទុកក្នុងវចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយ**ពុទ្ធសាសនបណ្ឌិត្យកម្ពុជា** ក្នុងឆ្នាំ **១៩៦៧**ត្រង់ទំព័រ**១០២**បានពន្យល់ថា ខោលជាល្ខោនពួកប្រុស រឿងរាមកេរ្តិ៍[៨] ។ ចំពោះលោក**ហ្សក សឺដេស** បានអោយនិយមន័យថា ល្ខោនខោលជាល្ខោននៃរបាំស្វា[៩] ។ ចំណែកអ្នកឧញ៉ា**ទេពវិទូរឈឹម ក្រសេមគជ្ជាបណ្ឌិត**វិញនៅក្នុងទស្សនាវដ្តីកម្ពុជសុរិយា**លេខ៣** ខែមីនាឆ្នាំ**១៩៤៨** លោកបានពោលថាចំណែកឯល្ខោនខោលនោះគេចូលចិត្តលេងរឿងដែលទាក់ទងនឹងរឿងព្រះជាម្ចាស់ គឺ**ព្រះឥស្វរព្រះនារាយណ៍**ដែលនៅក្នុង**សេយ្យសាស្រ្ត**គឺលេងរឿងអវតារបស់ព្រះជាម្ចាស់ដូចជារឿងរាមកេរ្តិ៍ សឹងជាប្រវត្តិរបស់ព្រះអម្ចាស់ ។នោះដើម្បីប្រកាសកិត្តិគុណសេចក្តីខ្លាំងពូកែ និងក្លាហានរបស់ព្រះជាម្ចាស់ ដែលបែងភាគមកកើតជាព្រះរាមជាដើម។ តាមក្បួនការសម្តែងរបាំនេះជាហេតុនាំមកនូវមង្គលសិរីដល់អ្នកលេង នឹងជាទី

ប្រោសប្រាណរបស់ព្រះជាម្ចាស់ ទើបគេនិយមលើលេងមកដល់ឥឡូវនេះ[៧០] ។ឯពាក្យខោលក្នុងជីវភាពប្រជាជនខ្មែរវិញគេនិយមប្រើពាក្យនេះសម្រាប់សម្គាល់គោ ឬក្របីដែលមានស្នែងខ្លីហើយចុះមកក្រោម ឬសម្គាល់សត្វស្វាកន្ទុយខ្លី ឬបើមិនដូច្នោះទេ ពាក្យខោលនេះគឺជាបញ្ញាត្តិសម្គាល់ទៅអាការៈដែលមិនបានព្រៀងទុកឬគិតទុកជាមុន ពោលគឺគិតឃើញភ្លាមធ្វើភ្លាមតែម្តង។ សំដីរបស់អ្នកប្រាជ្ញបណ្ឌិតនឹងការនិយាយរបស់ប្រជាជនកម្ពុជា ការដាក់បញ្ញាត្តិលើថាពាក្យខោលនេះមានលក្ខណៈសមហេតុផល ព្រោះបើយើងពិនិត្យទម្រង់ល្ខោនខោល ដែលសេសសល់ដល់សព្វថ្ងៃនេះយើងឃើញថាជាល្ខោនពាក់មុខរាំធ្វើកាយវិការឥតព្រៀងទុកជាមុនដើម្បីត្រាប់តាមពាក្យសម្តីរបស់អ្នកពោល ដែលជាអ្នករៀបរាប់អំពីដំណើររឿង។ ទម្រង់ល្ខោនខោលដែលត្រូវ សម្តែងមានតែសាច់រឿងតែមួយដូចល្ខោនស្រមោលស្បែកធំដែរ គឺសម្តែងរឿងរាមកេរ្តិ៍តែមួយមុខ គត់។ផ្ទៃនៃសាច់រឿងពោរពេញដោយតួអង្គស្វា ហើយនឹងយក្ស។ ពេលដែលគេនិយមសម្តែង គេសម្តែងក្នុងពិធី ត្រុស្តសង្ក្រាន្តជាពិធីផ្តាច់ឆ្នាំចាស់ចូលឆ្នាំថ្មី ដើម្បីបំបាត់ឧបទ្រព្យចង្រៃនៃឆ្នាំចាស់ ហើយសុំទេវតាឆ្នាំថ្មីជួយប្រទានពរដល់អាណាប្រជានុរាស្ត្រក្នុងដែនកម្ពុជារដ្ឋទាំងមូល ។ នឹងពេលខ្លះប្រទេសកើតគ្រោះរាំងស្ងួតគេក៏នាំគ្នារាំល្ខោនខោលដើម្បីសុំទឹកភ្លៀងផងដែរ។ម្យ៉ាងទៀតទម្រង់ល្ខោនខោលនោះជាទម្រង់ដែលមានសុទ្ធតែបុរសជានាក់រាំសូម្បីតែតួនាង**សីតា** នាង**មណ្ឌោគីរីជាជ័បុញ្ញកាយ** នាង**សុវណ្ណមច្ឆា**ក៏ដោយ។បើ

យើងមើលទៅតាមជញ្ជាំងប្រាសាទអង្គរវត្ត នឹងរូបភាពនៃល្ខោនខោលដែលសេសសល់ដល់សព្វថ្ងៃវិញ ដូចជាទេពស្វា យក្ស មេទព្វយក្ស ឬក៏ចលនាច្បាំងនៅក្នុងសង្គ្រាមរវាងទេពស្វានឹងទេពយក្សយើងសង្កេតឃើញថាមានលក្ខណៈដូចគ្នាស្ទើរតែទាំងអស់។ហេតុអ្វីបានជាគេ សម្ដែងសុទ្ធតែមនុស្សប្រុសទាំងអស់ដូច្នេះ? យើងគ្រាន់តែដឹងថាក្បាច់របាំបុរាណនៅសម័យអង្គរ ហៅថា**របាំ**នេះជាលទ្ធិទេវរាជគឺសម្ដែងក្នុងគោលបំណងបម្រើគាល់ថ្វាយទេព រាំថ្វាយទេពទើបគេនិយមហៅពួកស្រីរបាំនោះហៅថា ទេវទាសីបម្រើក្នុងទេវស្ថាន លុះដល់ពេលការប្ដូរសាសនាពីកាន់លទ្ធិព្រាហ្មណ៍និយមវិញការផ្លាស់ប្ដូរបែបនេះ ស្រីរបាំទាំងនោះនៅបន្តតួនាទីដែលតែនៅខាងព្រះពុទ្ធសាសនាមហាយានដោយផ្អែកលើសិលាចារឹក **ប្រាសាទតាព្រហ្ម** (សៀមរាប)និង **ប្រាសាទព្រះខ័ន** ដែលបានបញ្ជាក់ក្នុងសិលាចារឹកដែលខ្ញុំបាននិយាយម្ដងរួចមកហើយ។ ចំពោះក្រុមអ្នករបាំទាំងអស់នោះមិនត្រឹមតែអ្នករបាំទេ ថែមទាំងជាអ្នកចំលងពាក្យ បណ្ដឹងពាក្យបន់ស្រន់ នឹងពាក្យឧទ្ទិសទាំងឡាយពីឋានមនុស្សលោកទៅកាន់ឋានព្រះគឺឋានសួគ៍ ហើយពាំនាំពរសព្វសាធុការពីស្ថានសួគ៌ចុះមកប្រោសព្រំដល់មនុស្សលោកវិញ។ អ្នកទាំងនោះសុទ្ធតែជាអ្នកបរិសុទ្ធស្អាតមិនប្រឡាក់ប្រឡូកកដោយមន្ទិលសៅហ្មងផ្សេងៗ (មិនទាន់មានប្ដី)។ ចំណេរក្រោយមក បន្ទប់ពីការដាក់ចិត្តមកព្រហ្មណ៍សាសនាវិញក្នុងរជ្ជកាល **ព្រះចាជ័យវរ្ម័នទី៨** មន្ត្រីអ្នកមានអំណាច តែងដណ្ដឹងស្រីរបាំទាំងនោះធ្វើជាភរិយារបស់ខ្លួនដោយ

ការចាប់បង្ខំ ទង្វើបែបនេះនៅតែបន្តមានរហូតដល់មុនពេលប្រទេសកម្ពុជាផ្ទុះសង្គ្រាមឆ្នាំ ១៩៧០ ។ ដើម្បីចៀសវាងហានិភ័យនេះ គ្រូបាំបុរាណនាំគ្នាទៅជ្រកកោនក្រោមជីវភាពជារាស្ត្រធម្មតា ហើយបង្កើតជាទម្រង់ល្ខោនថ្មីមួយ ដោយយកតែប្រុសៗមកហាត់ប៉ុណ្ណោះ កុំអោយមន្ត្រីទាំងនោះមកបំផ្លាញបានទៀត។ ទាក់ទងនឹងបញ្ហាទាំងអស់នេះមានចំនុចពិសេសមួយ គឺជាការរកឃើញទម្រង់ល្ខោនខោលថាជាភាណីក្នុងសិលាចារឹកk៩៩ នាស.វទី១០ ពាក្យថា **ភ្នំ** (រូបលេខ)ឬ រមាំភាណីសុទ្ធតែជាសិល្បៈករប្រុសៗ នឹងពាក្យថ្មោងភាណីគឺតន្ត្រីករប្រគុំគ្រឿងភ្លេង សម្រាប់ល្ខោនភាណីក៏សុទ្ធតែប្រុសដែរ។ ពាក្យសំស្ក្រឹតភាណីគឺភាណៈ។ បើតាមវចនានុក្រម ខ្មែរសម្ដេចជួន **ណាត**ត្រង់ទំព័រ៨១៨ នោះបានអធិប្បាយថាភាណៈជា (ន)(បា)ដំណើរពោលការនិយាយការប្រាប់ការសូត្រ។ ឧទាហរណ៍ក្នុងរាជបវេណីមួយរបស់ព្រះរាជា តែងប្រារព្ធជាប់ជានិច្ចក្នុងព្រះបរមរជាវាំងពិធីសូត្រភាណយក្សា ដែលមានព្រាហ្មណ៍បុរោហិតនឹងព្រះសង្ឃផ្នែកព្រះពុទ្ធសាសនាជាអ្នកដឹកនាំ គេតែងប្រារព្ធនៅពេលមុនចូលឆ្នាំថ្មី។ ពាក្យថាភាណៈគឺជាការសូត្រ ឯពាក្យយក្សនៅទីនេះតំណាងអោយគ្រឿងមន្ទិលសៅហ្មងគ្រឿងអពមង្គលគ្រឿងអសោច៍និយាយអោយខ្លីអ្វីដែលអាក្រក់ទាំងឡាយ។ចំពោះពាក្យថាល្ខោនខោល ឬភាណីជាការនិយមហៅរបស់ប្រជាជនខ្មែរទូទៅពាក្យថាល្ខោនរាមកេរ្តិ៍ជាការនិយមហៅអ្នកបាត់ដំបងពាក្យថាល្ខោនយក្សរាំជាការហៅនិយមរបស់អ្នកកម្ពុជាក្រោម។ នេះគ្រាន់តែនិយាយតៗ

គ្នា តែប៉ុណ្ណោះវាមិនមានភស្តុតាងអ្វីមកបញ្ជាក់នោះទេ ប៉ុន្តែអ្វីដែលយើងគួរពិចារណា នៅក្នុងរាជព្រះបាទ ស៊ីសុវត្ថិមុនីវង្ស មានគ្រូរបាំស្រីៗជាច្រើននា ក់ក្នុងនោះអ្នកម្នាងជា សាម៉ីគឺជាតួឯងក្នុងរបាំក្នុងព្រះបរមរាជាវាំងពេលនោះសម្បូរមនុស្សហាត់របាំណាស់។ លុះចំណេរក្រោយមកដល់រាជកាលព្រះបាទសីហនុវរ្ម័ន អ្នកហាត់របាំក្នុងព្រះបរមរាជាវាំង កាន់តែច្រើន ឡើងៗទាំង ប្រុសទាំងស្រី របាំក៏ចាប់ផ្តើមមានមានការរីកចម្រើន តាំពីពេលនោះមក ។

## ក. ពេលចូលហាត់

ជាធម្មតាប្រពៃណីរបស់សិស្ស បើនរណាម្នាក់ប្រាថ្នាចេះរាំរបាំបុរាណ ត្រូវតែរៀបចំជារណ្តាប់សម្រាប់ជូនគ្រូមាន ដូចជា៖

-បាយសីប៉ាកឆាមមួយគូ

-ចេកមួយស្និត

-មាន់ស្ងោរមួយ

គ្រឿងរណ្តាប់ទាំងនេះសម្រាប់ជូនគ្រូរួមទាំងធូបទៀនទៅដល់គ្រូអ្នកបង្ហាត់បង្ហាញ ។ពេលនោះគ្រូបានយកទៀនធូបទៅអុជបូជាបួងសួងចំពោះលោកតាមុនីឥសី គ្រូតូច គ្រូធំហើយបញ្ចេញឈ្មោះកូនសិស្ស ដោយសុំអោយលោកជួយអោយពរអោយជ័យដល់កូនសិស្សអោយឆាប់រៀនចេះមានឈ្មោះល្បីល្បាញ(រូបលេខ)។ សម្រាប់ក្បាច់បាត(ក្បាច់មូលដ្ឋាន) បើសិស្សចាស់ៗ ចង់ហាត់ក្បាច់ធំៗ

ឬតួឯក ត្រូវជូនរណ្តាប់ទៅគ្រូម្តងទៀត ការជូននេះគឺជូនតាមដំណាក់កាលនៃក្បាច់របស់តួអង្គនីមួយៗ។

**៚ តួនាង(តួស្រី)ត្រូវជូនបាយសីមួយថ្នាក់មួយគូៈ**

-ចេកមួយស្និត

-ផ្លែឈើផ្សេងៗ

-ពងមាន់មួយ

-ទៀនមួយដើម

-ធូបប្រាំ ឬប្រាំពីរសរសៃ

**៚ តួនាយរោង(តួប្រុស)ត្រូវជូនៈ**

-បាយសីមួយថ្នាក់ប្រាំគូ

-ក្បាលជ្រូកស្ងោរមួយ

-មាន់ស្ងោរមួយ

-ផ្លែឈើ

-ទៀនមួយដើម

-ធូបប្រាំ ឬប្រាំពីសរសៃ

**៚ តួយក្សត្រូវជូន**

-បាយសីប្រាំពីរ ឬប្រាំបួនថ្នាក់មួយគូរ

-ក្បាលជ្រូកឆៅមួយ

-មាន់ឆៅមួយ

-ផ្លែឈើ
-ទៀនមួយដើម
-ធូបប្រាំពីរ ឬប្រាំពីរសរសៃ

## ១ ពេលហាត់

អ្នកដែលមិនចេះសោះតែម្តង គេត្រូវអោយរៀនចំពីក្បាច់បាតជាក្បាច់មូលដ្ឋានសិន ដោយគ្រូជាអ្នកមើលការពត់ខ្លួន ឈរជៀវជាដើម តើត្រឹមត្រូវដែលឬអត់ ប៉ុន្តែគ្រូរបាំភាគច្រើនកាចៗណាស់តាំងពីដើមមក បើសិស្សនោះធ្វើមិនកើតទេគាត់អាចក្តិច មួល ដើម្បីអោយឆាប់ចាំក្បាច់ទាំងអស់នោះ(រូបលេខ)។និយាយខ្លីទៅការហាត់នេះតម្រូវអោយមានគ្រូធំៗមើលការខុសត្រូវគ្រប់សព្វ ឯគ្រូរបាំភាគច្រើនសុទ្ធតែជាមនុស្សស្រីមានវ័យចំណាស់ ចំណែកសិស្សរបាំទាំងនោះកោតញញើតខ្លាំងណាស់ ហើយគ្រូចាស់ៗទាំងនោះសឹងតែជាអ្នករាំស្ទាត់ជំនាញពីមុនមក។ទោះបីគាត់មិនមែនជាគ្រូធំបង្អស់ក៏ដោយតែគាត់មានភារកិច្ចជួយពត់ខ្លួន ពត់ដៃ ពត់ជើង ដល់សិស្សរបស់គាត់ធ្វើយ៉ាងនេះដើម្បីអោយត្រូវតាមក្បួនខ្នាតប៉ុណ្ណោះពោលគឺទម្រង់ដើមនៃក្បាច់(រូបលេខ)។ ពេលណាគេហាត់ក្បាច់បាតនេះចាំស្ទាត់អាចរាំបានហើយ គ្រូតែងតែបង្ហាត់ក្បាច់ធំ ឬក្បាច់តួមាន តួយក្សតួនាង តួនាយរងតួស្វាជាដើម។ប៉ុន្តែពេលហាត់ក្បាច់ទាំងនេះត្រូវតែមានការតស៊ូអត់ធ្មត់អោយបានច្រើន ទើបការហាត់ឆាប់ចេះចាំ ព្រោះការទាមទារ អោយមានការពត់ខ្លួនដៃជើងជារៀងរាល់ថ្ងៃរហូតមានពាក្យគេតែងនិយាយចំអកគ្នាថាអ្នករបាំនិងគូទងដាក់ក្អមបាន។

## គ. របាំងមុខ

ការសម្តែងនៅឆាក បើយើងគិតអោយវែងឆ្ងាយទៅគឺអ្នកសម្តែងនោះធម្មតាជាបុគ្គលធម្មតាទៀតឡើយ មិនមែនជាបុរស ក នារី ខ ដែលយើងឃើនៅឆាកនោះទេ ។ កន្លែងដែលដំណើរប្រព្រឹត្តិទៅ ក៏មិនមែនជាឆាកដែលយើងឃើញនោះទេ ព្រោះអ្វីទាំងអស់នោះត្រូវគេសន្មតជារបស់ថ្មីទាំងអស់ ហើយជាអ្វីដែលយើងនឹកស្មានមិនដល់នោះគឺតួអង្គទាំងនោះលែងជាមនុស្សធម្មតា លែងជាអ្នកសម្តែងរបាំទៀតហើយ មានន័យថាពួកគេគឺជាបានរំលាយខ្លួនទៅជាតួអង្គ **ព្រះរាម សីតា ហនុមាន ពិភេក ក្រុងរាពណ៍** ជាដើម ។ ហើយឆាកសម្តែងនោះសោតគឺជាភ្នំចិត្រកូដកាលជំនាន់នោះមិនមែនជាឆាកដែលយើងកំពុងទស្សនាទេ ព្រោះតែជាការស្តែង[១១] ។ ការផ្លាស់ប្តូរបែបនេះគឺដោយសាររបាំងមុខ ការគួរមុខ ស្រោមមុខជាដើមព្រោះរបាំងមុខនេះបានប្តូរអាត្មា ទៅអាត្មាទីទៃមួយទៀតពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត លែងជាបុរស ក នារី ខ ទៀតឡើយពេលណាដែលពាក់របាំងមុខនឹងគួរមុខ។ពេលមានបុគ្គលធ្វើមរណកាល គេតែងយកក្រណាត់សប្រវែងមួយចំអាម មកគ្របពីលើមុខសព បើព្រះរាជាគេប្រើរបាំងមុខធ្វើអំពីមាសទៅគ្របពីលើព្រះភក្ត្រ នេះមានន័យថាជាការបញ្ជាក់ពីភាពខុសគ្នារវាងមនុស្សស្លាប់និងមនុស្សរស់[១២] ។ ជាទូទៅរបាំងមុខទាំងអស់សុទ្ធតែធ្វើអំពីឌុកដែលមានច្រើនប្រភេទណាស់ ដូចជាយក្ស ឥសី គ្រុឌ និងរូបផ្សេ

ងៗសុទ្ធតែត្រូវបានគេគោរពបូជាយ៉ាងខ្លាំងណាស់មិនអាចយកទៅ ដាក់ចោលនៅទីនេះ ទីនោះផ្តេសផ្តាសបានឡើយ។បើមុខឥសីវិញ កាន់តែគោរពខ្លាំងមែនទែន ព្រោះជាគ្រូធំ ដូច្នេះការពាក់មុខរាំរបាំ ការលាបម្សៅ ការគូរមុខនេះមិនត្រឹមតែអោយសោភ័ណភាពតួអង្គ តែប៉ុណ្ណោះទេ គឺប្តូរខ្លួនតួអង្គទៅកាន់បរិបទផ្សេងមួយទៀត។

## ឃ. របៀបធ្វើមុខខ្នុក



រូបលេខ៖១៧-១៩





ាំងភ្លា
ាលា
ាមួយ
ដ្ឋមក

សូនជារូបដែលគេត្រូវការ រូបសូនចេញជារូបរាងនោះគេហៅថាពុម្ព ឈ្មោល(រូបលេខ១៨) ពេលបានពុម្ពឈ្មោលហើយ គេក៏យកស៊ីម៉ង់ត៍ ទៅប៉ាតជុំវិញអោយសព្វគេហៅថាពុម្ពញី បន្ទាប់គេយកក្រដាស្មាច់

ជាមួយនិងបាយមកបិតជុំវិញរូបនោះមួយចំហៀងម្តង រួចទើបគេយកទៅហាលថ្ងៃ តែមិនត្រូវហាលអោយស្ងួតពេកឡើយគឺស្រពាប់បន្តិចបានហើយ ។ គេអាចបិទក្រដាសស្នាច់នោះកម្រាស់តាមដែល [illegible] ថ្ងៃគ្រប់តាមចំនួនកំណត់(រូបលេខ១៩) [illegible] កម្រឹមគ្រែមខាងក្រោមអោយចង្កា [illegible] ក។



រូបលេខ៖១៨



រូបលេខ៖១៩

បន្ទាប់មកគេយកមុខខ្នុកនោះដេរភ្ជាប់គ្នា ដោយក្រដាសស្នាច់លើឆ្អុតមុខតំណាទើបគេចាប់ផ្តើមបំពាក់ក្បាច់ ផាត់ពណ៌ផ្សេងៗទៅតាមតួអង្គនីមួយៗមាន៖

_ ព្រះមុនីឥសី ពណ៌សាច់ ។

_ ព្រះរាម ពណ៌បៃតងចាស់ ម្កុដមាស។
_ ព្រះលក្សណ៍ ពណ៌ផ្កាឈូក ម្កុដមាស។
_ ហនុមាន ពណ៌ស មាត់ហា។
_ សុគ្រីព ពណ៌ទឹកក្រូច ម្កុដមាសកំពូលស្រួច ហាមាត់។
_ អង្គត ពណ៌បៃតងចាស់ម្កុដមាស កន្ទុយហង្សមាត់បិទ។
_ និលឯកស្វា មុខខ្មៅពេជ្រម្កុដមាសកន្ទុយហង្សមាត់បិទ។
_ និលផាត់មច្ឆាទេព ស្វាពណ៌មាសមានកន្ទុយត្រី។
_ សិម្ពិលីត្រុឌ មុខត្រុឌពណ៌គ្រប់អំពិល។
_ ក្រុងរាពណ៍ ពណ៌បៃតងចាស់ឬពណ៌មាសម្កុដមានមុខ
ដប់ខាងលើបំផុតគឺមុខព្រហ្ម។
_ កុម្ពិកា យក្ខពណ៌គ្មានម្កុដតែមានឆ្នូតពណ៌មាសសក្រែង
ពណ៌មាស។
_ ឥន្ទ្រជិត យក្ខបៃតងម្កុដស្រួចពណ៌មាសមានសៀតកន្ទុយ
ហង្ស។
_ ឥរាមឥសូរ យក្ខពណ៌បៃតង ម្កុដកន្ទុយហង្ស។
_ សូបនខា យក្ខស្រីពណ៌បៃតងចាស់ ក្បាំងនឹងមាន ចន ព
ណ៌មាសទេស៍។

## ជ .ការតុបតែងតួអង្គ

ចំពោះការតុបតែងខ្លួនតួអង្គ ធ្វើយ៉ាងណាអោយមានភាពលេចធ្លោស្អាតអស្ចារ្យ លើសពីមនុស្សធម្មតាទាំងការស្លៀកពាក់ ទាំងគ្រឿងអលង្ការសម្រាប់តុបតែងខ្លួនក៏មានលក្ខណៈប្លែកជាងមនុស្សធម្មតាដែរ ។ ចំពោះការស្លៀកពាក់មានការពិបាកណាស់ទាល់តែមានអ្នកជួយស្លៀកជួយដេរនឹង សម្រាប់លម្អតួអង្គអោយក្លាយទៅជាទេព ។ សម្រាប់តួអង្គដែលត្រូវយកមកសម្តែងគេមិនសូវរើសយកតែតួស្អាតពេកទេ ព្រោះតួអង្គទាំនោះសុទ្ធតែត្រូវពាក់មុខទាំងអស់ លើកលែងតែតួនាងតែប៉ុណ្ណោះដែលមិនពាក់មុខទេ តែត្រូវលាបម្សៅអោយសក្រាស់លើមុខ(រូបលេខ៣៥)។តួអង្គដែលសមក្នុងការសម្តែងគឺ៖

- តួយក្សត្រូវអ្នកដែលមានមាឌធំដំបង ស្វាហាប់
- តួអង្គហនុមានត្រូវយកអ្នករហ័សសង្ហា ស្វាហាប់

- តួពលស្វា ត្រូវយកក្មេងៗមាឌល្អិតៗ រហ៊ុលរប៉ូច
- តួអង្គនាយរោង ត្រូវរើសយកអ្នកដែលមាន រាងខ្ពស់

## ច. រានហាល ឬ ក្ដារបែន

នៅស្ទើរតែគ្រប់ប្រាសាទដែលជាទេវស្ថានទាំងអស់សុទ្ធតែ មានរានហាល ឬក្ដារបែន ដែលជាកន្លែងដែលសម្រាប់រាំរបាំថ្វាយអាទិទេពក្នុងបរិវេនកំពែងប្រាសាទរនៅមុខទ្វារចូលទៅតួប៉ម កណ្ដាលប្រាសាទតែម្ដង ។ ជាក់ស្ដែងយើងឃើញនៅប្រាសាទអង្គរតូច (វិស្ណុលោក)មានក្ដារ បែនឬរានហាលយ៉ាងធំខ្ពស់បែរមុខទៅទិសខាងលិច ស្ថិតនៅចំមុខប្រាសាទធំ ដែលមានទ្រង់ទ្រាយជាកាកបាទ (ជើងឯក)(រូបលេខ២០)ដែលមានលម្អដោយសត្វនាគ និងបង្កាន់ដៃសងខាង ។ ពាក្យថាក្ដារបែននេះមានពាក្យម៉្យាងទៀតហៅថា **រានហាល** គឺជារានសង់ពីថ្ម រៀបអោយខ្ពស់ពីដីមានបង្កាន់ដៃ ឬគ្រឿងលម្អផ្សេងៗ តែពុំមានប្រក់ដំបូលទេហើយនៅជាប់ពីមុខប្រាសាទ ឬទីសក្ការអ្វីមួយ(រូបលេខ២១) ។ ជួនកាលកន្លែងសម្រាប់តភ្ជាប់ពីក្លោងទ្វារទៅនឹងប្រាសាទ ឬពីសំណង់មួយទៅសំណង់មួយទៀតក៏គេហៅថា **រានហាល** ដែរ។



រូបលេខ២០៖ក្តារបែននៅមុខប្រាសាទអង្គរវត្ត



រូបលេខ២១៖រានហាល
នៅខាងប្រាសាអង្គរវត្ត

ឯសម័យកាលក្រោយៗមក គេក៏តែបន្តទ្រង់ទ្រាយក្តារបែនជាកាកបាទដដែល តួយ៉ាងដូចនៅប្រាសាទបាយ័ន គេកសាងនៅទិសខាងកើតគឺច្រកចូលប្រាសាទធំ នៅទីនោះមានស្រះទឹកពីរអមសងខាងផង ។ ចំណែកនៅប្រាសាទតាព្រហ្មដែលជាទីសក្ការមួយ

ក្នុងចំណោមទិសក្ការធំៗរបស់ពុទ្ធសាសនិក សម័យនោះក្ការបែនឬ រានរាំនេះដែរ(រូបលេខ)។

នៅប្រាសាទព្រះខ័ន ដែលកសាងដោយព្រះបាទជ័យវរ្ម័នទី៧ រានរាំ ឬក្ការបែននៅតែមានសណ្ឋានទ្រង់ទ្រាដូចនឹងប្រាសាទ ដែលបានលើកមកខាងលើដែរ ។ លុះចំណោរកាលក្រោយមករានរាំ ត្រូវបានគេជ្រើសរើសយកលើទីទួលកណ្ដាលវាលសម្រាប់សម្ដែង តែពុំមានដំបូលពុំមានជញ្ជាំងទេ គឺគ្រាន់តែក្រាលកន្ទេលសម្រាប់អ្នកសម្ដែងតែប៉ុណ្ណោះ ។ មកដល់បច្ចុប្បន្នគេលែងទៅសម្ដែងនៅមុខប្រាសាទទៀតហើយ គេតែងទៅសម្ដែងនៅសាលមហោស្រព ជាដើម ។

# ៨ ពេលសម្ដែង

ការសម្ដែងផ្ដើមដោយការរំឭកគុណគ្រូជាមុនសិន ដោយតម្រូវអោយសិល្បករសិល្បការិនីទាំងអស់ ដែលត្រូវសម្ដែងមកកាន់ខាងមុខឆាកជាកន្លែងហោមពិធីរំឭកគុណគ្រូ ។ ពេលនោះគេត្រូវយកមុខរបាំទាំងអស់មកដាក់លើអសនៈ រូបព្រះមុនីឥសី គេត្រូវដាក់នេះនៅចំកណ្ដាលហើយខ្ពស់ជាងរូបដ៏ទៃទៀត ។ ការប្រកាសអញ្ជើញទេព្ដាបែបខ្លី បើភ្លេងសាធុការបន្លឺឡើងបញ្ចប់ពិធីហោមរោង ក្រុមអ្នកសម្ដែងទាំងអស់ត្រូវលើកដៃឡើងសំពះទាំងអស់គ្នា ។ ទើបគេរើមុខទាំងនោះយកតាមតួអង្គដែលត្រូវសម្ដែងរៀងៗ

ខ្លួន ។ ចំណែកមុខព្រះមុនីឥសីគេត្រូវរកកន្លែងដ៏សមរម្យសម្រាប់ដាក់ ព្រោះជាគ្រូធំចម្បងក្នុងសិល្បៈនេះ។ បទផ្លិបន្លីឡើងជាសញ្ញាទើបផ្ដើមចេញការសម្ដែងរបស់តួអង្គទៅតាមឈុតតែម្ដង។ការសម្ដែងនោះគឺគួបផ្សំជាមួយនឹងការពោលរៀបរាប់ពីសកម្មភាពឥរិយាបថរបស់តួអង្គផងដែរ។ឯការពោលក្នុងទម្រង់ល្ខោនខោលនេះយើងឃើញគេច្រើនប្រើពារបៀបៈ

-ការពោលជាកំណាព្យ

-ការពោលជាកម្រងកែវ

- ការពោលជាពាក្យរាយ។

# ជំពូក៣ គ្រូជំបង្អស់ក្នុងសិល្បៈរបាំបុរាណ

ដូចដែលយើងបានដឹងស្រាប់ហើយ អ្វីក្នុងលោកនេះគ្មានអ្នកណាកើតឡើងចេះដឹងសព្វគ្រប់ដោយខ្លួនឯងឡើយ លុះត្រាតែមានការបង្ហាត់បង្រៀនអំពីសំណាក់គ្រូអាចារ្យ ទើបយើងចេះរែកញែករក ល្អ អាក្រក់ គុណ ទោស បាប បុណ្យ ខុស ត្រូវ វិជ្ជាផ្សេងៗបាន ។ យ៉ាងណាមិញការសិក្សារៀនសូត្របហាត់ពត់លត់ដំកាយអោយមានសភាពទន់ភ្លន់ចេះបត់បែនកាច់ទៅជាក្បាច់របាំអាចរាំអាចសម្ដែងចែកជូនជនានុជនអោយទស្សនាបាន មិនមែនជារឿងចៃដន្យ មិនមែនចេះយ៉ាងល្អដោយគ្មានគ្រូបង្ហាត់បង្រៀនទើបបានជាផ្លែផ្កានោះទេ ។ បើមិនមានគ្រូជាដឹកនាំជួយបង្ហាត់បង្រៀនទេ ក៏មិនអាចធ្វើបានល្អដែរ ។ ដូច្នេះគ្រូគឺជាបុគ្គលដ៏សំខាន់ម្នាក់ដែលយើងត្រូវតែគោរពបដិបត្តិចំពោះរូបគាត់ ។ ប៉ុន្តែគំនិតអំពីគ្រូដដែលនេះ វាមិនខុសអ្វីពីបុព្វការីជននោះឡើយ ព្រោះថាបើយើងសួរដេញដោលវែងឆ្ងាយថាគ្រូសព្វថ្ងៃចេះរបាំនោះមកពីនរណា ? គាត់ច្បាស់ជានិយាយថាចេះពីគ្រូ របស់គាត់ បើយើងសួរបន្តទៀតច្បាស់គាត់ថាចេះតៗគ្នាមក ។ បើយើងទៅពិនិត្យមើលសិលាចារឹកនាសម័យបុរាណវិញក៏មានអ្នករាំរបាំដូចជា នៅនៅប្រាសាទលលៃ ស.វទី៩ គេឃើញពាក្យថា**ភ្នំ**ស្មើនឹងពាក្យបច្ចុប្បន្ន**អ្នករាំ**(រូបលេខ៦៤) នឹងពាក្យច្រៀងហៅថា**ចយ៉្យង**(រូបលេខ៦៥) មានន័យថារបាំមានតាំងពីយូរណាស់មកហើយដូចមានក្នុងជំពូកមុនស្រាប់ ។ តែបើយើងសួរ

ដេញរកអំពីគ្រូធំបង្អស់ក្នុងសិល្បៈរបាំនេះជានរណា គេតែនិយាយថាជា**ព្រះមុនីឥសី** ។ វាពិតជាត្រឹមត្រូវណាស់ហើយដែលគេគោរពកោតក្រែងរូបព្រះមុនីឥសី ជាគ្រូធំបងអ្ហស់នោះព្រោះនៅពេលតាំងពិធីអ្វីមួយដែលជាប់ទាក់ទងនឹងសិល្បៈ គេមិនចោល**លោក តាមុនីឥសីឬព្រះមុនីឥសី**ឡើយ ។ លោកតា**មុនីឥសី**ព្រះមុនីឥសីមានអានុភាពខ្លាំងក្នុងទម្រង់ល្ខោនស្បែកទាំងអស់ មុនពេលដាប់ស្បែកធ្វើរូបតួអង្គណាមួយគេត្រូវរៀបព្រះពិស្ណុ ការថ្វាយទៅដល់ព្រះពិស្ណុការគឺលោកតា**ព្រះមុនីឥសី** ។ ពេលដែលចាប់ផ្ដើមសម្ដែងភាពស្បែក គេចាំបាច់ត្រូវតែមានស្បែករូបប**ព្រះមុនីឥសី** ឬស្បែកស្ដេចមកធ្វើពិធីហោមរោង ព្រោះលោកតា**ព្រះមុនីឥសី**ជាគ្រូធំបង្អស់ក្នុងទម្រង់សិល្បៈនេះ ។ រីល្ខោនខោលវិញពេលគេទទួលសិស្សអោយចូលហាត់ គ្រូអ្នកទទួលតែងដុតធូបសំបូងសង្រួងទៅកាន់លោកតា**ព្រះមុនីឥសី**អោយទទួលសិស្សនេះ ផង ហើយសូមអោយរៀនក្បាច់ឆាប់ចេះចាំ ។ នៅពេលសម្ដែងគេយករបាំងមុខលោកតា**ព្រះមុនីឥសី**ដាក់កម្ពស់ទីខ្ពស់ជាង មុខដទៃទៀតក្នុងគំនិតថាជាគ្រូធំបង្អស់ក្នុងទម្រង់សិល្បៈខោល ។ ពេលធ្វើរបាំងមុខល្ខោនខោល ចាប់ផ្ដើមដំបូងគេត្រូវរៀបចំជាស្លាជមសម្រាប់ព្រះពិស្ណុការ ប៉ុន្តែព្រះពិស្ណុការនេះមិនមែនជាព្រះវិស្ណុទេ គឺលោកតាព្រះមុនីឥសីដែលគេសម្គាល់ថាជាគ្រូធំបង្អស់របស់គេ ។ ម្យ៉ាងទៀតក្នុងសិល្បៈខ្មែរបុរាណគេចាត់ទុក**ព្រះឥសូរ ដ៏ព្រះនរាយណ៍** ជាទេពធំជាងគេហើយគេនិយមរាប់អាចជាងទេពដ៏ទៃទៀតក្នុងព្រហ្មញ្ញសាសនា ។ តាមរយៈ

ចម្លាក់រឿងបុរាណជាច្រើនគេតែងលើកតម្កើង **ព្រះនរាយណ៍** **ព្រះឥសូរ** យ៉ាងខ្លាំងដូចជារឿងកូរសមុទ្រទឹកដោះនៅតាមជញ្ជាំងហោជាង បង្កាន់ដៃ និងផ្តែរ (រូបលេខ) **ព្រះនរាយណ៍** ផ្ទំកណ្តាលសមុទ្រ **ព្រះឥសូរ**ស្ទឹងស្មាធិ៍លើភ្នំកៃលាស **ព្រះឥសូរ**ជិះគោនន្ទិជាមួយ**នាងឧមា**(រូបលេខ ) ឯចម្លាក់ដែលគួរអោយចាប់អារម្មណ៍បំផុតនោះគឺរូប**ព្រះឥសូរ**រាំ សឹងមានតែគ្រប់ទិសទីទាំងអស់ក្នុងអាណាចក្រខ្មែរសម័យអង្គរ(រូបលេខ )រហូតមានសិលាចារឹកមួយបានហៅ**ព្រះឥសូរ**រាំនេះឈ្មោះថា **កម្រតេងអញតរាំ** ភាសាសំស្ក្រឹតហៅថា **នាដរាជ** (ទេពនៃការរាំ) ។ ក្នុងទេវកថាព្រាហ្មណ៍និយមមួយបានថែងថាការរាំរបស់ទេពទាំងអស់ សុទ្ធតែមិនមានបំរើអោយការសប្បាយនោះទេគឺក្នុងគោលបំណងតែមួយគត់ ដើម្បីកំចាត់បង់នៅសភាវអាក្រក់ ឧបទ្រពនានា ហេតុនេះបានជាខ្មែរប្រកាន់យកទំនៀមបែបនេះមករហូត ។ ប្រសិនណា**ព្រះឥសូរ**ជាគ្រូធំបង្អស់នៃរបាំ ហេតុអ្វីបានជាពេលគេរៀបចំរណ្តាប់បូជាគ្រូ គេតែងដាក់រូបឥសីក្នុងជាន់ខ្ពង់ខ្ពស់ប្រសើរជាងគេទៅវិញ ។ ដើម្បីយល់ពីបញ្ហានេះ តោងអោយយើងស្គាល់ពីលក្ខណៈរបស់ព្រះឥសូរជាមុនសិន ។ លក្ខណៈសម្គាល់ព្រះមានច្រើនប្រភេទណាដូចជា៖

-ចំណិតព្រះខែនៅលើផ្នួងព្រះកេសា នឹងព្រះនេត្រទីបីរបស់ទ្រង់ (រូបលេខ២២) ។

-ត្រីសូល៍ ដ្បិតអាវុធនេះជាគ្រឿងសម្គាល់ព្រះអង្គ (រូបលេខ២៣) ។

-ទេពដែលគង់នៅលើគោនឹងមានបាងឧមាគង់ជាមួយផង (រូបលេខ២៤)។

-សូម្បីតែគោនន្ទិដែលជាយានជំនិះទ្រង់ក៏ជានិមិត្តរូបតំណាងអោយព្រះឥសូរដែរ (រូបលេខ២៥) ។

-ទេពដែលអង្គុយទ្រជាយានៅលើភ្លៅ ក៏ជាព្រះឥសូរដែរ (រូបលេខ២៦) ។

-ទេពដែលរាំក៏ជាព្រះឥសូរដែរវៀរលែងតែនៅលើហោជាងប្រាសាទយាយពៅមួយតែប៉ុណ្ណោះជារូបព្រះវិស្ណុរាំ (រូបលេខ២៧) ។

-ព្រះឥសូរក្នុងរូបរាងជាតាបសនៅចំកណ្តាលតាបសដ៏ទៃទៀត (រូបលេខ២៨) ។

-ទេពដែលមានមួយចំហៀងជាស្រី មួយចំហៀងជាប្រុស តាមគម្ពីរឥណ្ឌាហៅទិដ្ឋភាពនេះថា **អធ៌្ននារីឝ្វរ** (ព្រះជាម្ចាស់ស្រីពាក់កណ្តាល) គឺផ្នែកខាងស្តាំជាប្រុស ខាងឆ្វេងជាស្រី (រូបលេខ២៩) ។

-ទេពមួយដែលកើតចេញពីការរួមបញ្ចូលគ្នារវាង**ព្រះវិស្ណុ ហរិ** នឹង **ព្រះឥសូរ ហរ** បានជាទេពមួយអង្គមានព្រះនាមថា **ហរិហរ** (រូបលេខ៣០) ។

-**ព្រះឥសូរ**ក្រោមរូបភាពជាលិង្គ ជាការបញ្ជាក់អោយឃើញពីការបង្កើតភគផល ។ លិង្គនោះមានរាងប្រាំជ្រុងក្រោមបួនជ្រុងកណ្ដាលខាងលើមូល ជួនកាលគេដាប់រូបព្រះភក្ត្រព្រះអង្គពីលើថែមទៀត(រូបលេខ៣១) ។

-ថ្មធម្មជាតិដែលដុះលយចេញពីផ្ទៃថ្មរាបស្មើណាមួយ ក៏គេចាត់ទុកជាព្រះឥសូរដែរគេហៅថា**ស្វយម្ភូលិង្គ** (រូបលេខ) ។

លើសពីនេះព្រះឥសូរក៏អាចស្ថិតនៅក្នុងទិដ្ឋភាពបីយ៉ាងទៀតដូចជា៖

-ព្រះឥសូរមានសភាពកាចសាហាវយកក្បាលខ្មោចមកធ្វើជាខ្សែកមានពស់វែកពាក់លើស្មារូបរាងអាក្រាតកាយ កាលដែលព្រះអង្គកើតជាស្មូមយាចក (រូបលេខ) ។

-ព្រះឥសូរជាអ្នកសង្គ្រោះលោកមានព្រះភក្ត្រញញឹម ចរិតស្លូតបូត ។

-ព្រះឥសូរមានរូបរាងជាឥសី ។ ក្នុងចំណោមទិដ្ឋភាពទាំងបីនេះខ្មែរយើងនិយកទទួលយកតែទិដ្ឋភាពពីរប៉ុណ្ណោះ គឺព្រះឥសូរមានព្រះស្លូតបូត ១ និងព្រះឥសូរមានរូបរាងជាឥសី ១ ។

សរុបមកបណ្ដាលទិដ្ឋភាពទាំងនេះ យើងឃើញថាព្រះឥសូរគឺឥសី ដោយនៅក្នុងផ្នត់គំនិតខ្មែរបុរាណពាក្យថា ឥសីគឺសំដៅទៅលើគ្រូតែម្ដង ។ ក្នុងរឿរាមកេរ្ដិ៍ខ្មែរនិងរាមាយណៈឥណ្ឌា ព្រះរាមទៅ

រៀនមន្តវិជ្ជាការផ្សេងៗពីសំណាក់ ឥសី ដែលជាគ្រូបង្ហាត់បង្រៀនទ្រង់ ។ ដូច្នេះឥសីគឺជាគ្រូ ប៉ុន្តែនៅក្នុងព្រះពុទ្ធសាសនាគ្រូបង្រៀនគឺអាចារ្យទិសាបាមោក្ខ ហេតុនេះហើយវាគ្មានគួរអោយងើងឆ្ងល់ទៀតឡើយនៅពេលដែលគេចាត់ទុកព្រះមុនីឥសីគ្រូចំបង្អស់ ព្រោះព្រះមុនីឥសីគឺជាព្រះឥសូរ ។



រូបលេខ៖២២



រូបលេខ៖២៣



រូបលេខ៖២៤




រូបលេខ៖២៥ រូបលេខ៖២៦




រូបលេខ៖២៧ រូបលេខ៖២៨




រូប

លេខ៖២៩-៣០



រូបលេខ៖៣១



រូបលេខ៖៣២



រូបលេខ៖៣៣



រូបលេខ៖៣៤



រលេខ៖៣៥-៣៦

ចុះហេតុអ្វីមិនថាព្រះវិស្ណុ ថាជា ឥសីទៅ ?ព្រោះវិស្ណុ មានការបែងភាគជាអវតារ មាន១០យ៉ាង៖

–មត្ស្យៈ(ត្រី)

–កូម៌(អណ្តើក)

–វរាហៈ (ជ្រូកព្រៃ)

–នរសិង្ហ (មនុស្សក្បាលសិង្ហ)

–វាមនៈ (មនុស្សតឿ)

–បរាសុរាម (មនុស្សកាន់ពូថៅ)

–ព្រះរាម

–ពលរាម(ទេពលីនង្គ័ល)

-គ្រីស្នៈ (ក្មេងគង្វាល)

-ព្រះពុទ្ធ

-កល្កិន(មនុស្សក្បាលសេះ)

តាមរយៈការបែងភាគទាំងដប់របស់ព្រះវិស្ណុ  គ្មានអវតាណាមួយក្នុងទិដ្ឋភាពឥសីសោះដូច្នេះនេះសបញ្ជាក់អោយឃើញរឹតតែច្បាស់ថាព្រះឥសូរគឺជាធំបង្អស់ក្នុងសិល្បៈរបាំក្បាច់ខ្មែរបុរាណ ។

# ជំពូក៤ វិស័យវេជ្ជសាស្ត្រជាសម័យបុរាណ

*វេជ្ជ ជាភាសាបាលី ស្មើនឹងពាក្យសំស្ក្រឹត វៃទ្យ ខ្មែរក្លាយជាពាក្យ* **ពេទ្យ** *មានន័យថាជាអ្នកចេះអាយុវេទ(វិជ្ជាសម្រាប់រក្សាអាយុ)[១២]។ចំណែកពាក្យថា សាស្ត្រក្លាយមកពីពាក្យ* **សត្ថ,ឝាស្ត្រ**, *ជាគម្ពីរ ,ក្បួន, តម្រា, វិជ្ជា ,ការសិក្សា,ពាក្យណែនាំ, ពាក្យពន្យល់, ពាក្យបង្គាប់ [១៣] ។ រួមសេចក្តីមក វេជ្ជសាស្ត្រសំដៅយកក្បួន តម្រា ការណែនាំ ការបង្គាប់បញ្ជា ការសិក្សា ការពន្យល់ពីការរក្សាអាយុ ក្នុងគោលបំណងអោយជីវិតរស់នៅ ប្រកបដោយប្រណិតភាពយ៉ាងល្អ ប្រពៃជៀសចាកពីមន្ទិលគឺរោគទាំងឡាយដែលកើតឡើងពីសមុដ្ឋាននៃរោគ(ហេតុនាំអោយកើតរោគ)ទៅតាមបែបបទនៃការព្យាបាលដែលបានចេះចាំតៗគ្នាតាមរយៈក្បួនច្បាប់ជាក់លាក់តាំងពីបុរាណរហូតមកដល់បច្ចុប្បន្ននេះ។*

*សុខភាពល្អគឺជាប្រណិតភាពម៉្យាងរបស់មនុស្សគ្រប់ស្រទាប់វណ្ណៈទាំងអស់មិនថាមន្ត្រីរាជការ ព្រះមហាក្សត្រ ពាណិជ្ជករ ប្រជារាស្ត្រសាមញ្ញ សុទ្ធសឹងតែប្រាថ្នាចង់បាននូវភាពក្នុងភាពប្រណិតក្នុងជីវិតទាំងអស់គ្នា ។ដើម្បីបានភាពប្រណិតនេះមកភពប្រសព្វមកលើខ្លួន ម្នាក់ៗប្រឹងប្រែងរកគ្រប់វិធីសាស្ត្រ មធ្យោបាយ ទោះជាលំបាកលំបិនយ៉ាងណាក៏ដោយ ក៏សុខចិត្តពុះពារគ្រប់បែបយ៉ាងដើម្បីទទួលបានសុខភាពល្អ។ សុខភាពគឺជាបញ្ហាចម្បងបំផុតរបស់មនុស្សទាំង*

អស់ក្នុងសាកលលោកមិនថាប្រទេស ថៃ ឡាវ ចិន កម្ពុជា សុទ្ធតែជឿសមិនផុតទាំងអស់គ្នា ហើយបញ្ហានេះក៏មិនមែនបណ្ដោយទំជាប់ប្រាណដូច្នេះឡើយ គឺមនុស្សតែងតែរិះរកមធ្យោបាយដើម្បីព្យាបាលរោគទាំងអស់នោះស្ងប់រម្ងាប់ដោយឱសថជាដើម។ ប៉ុន្តែជួនកាលវិធីព្យាបាលជំងឺទាំងនោះអាចទៅពិគ្រោះជាមួយពេទ្យដែលជាអ្នកឈ្លៀសវៃផ្នែកវិជ្ជារក្សាអាយុ ដើម្បីរកឱសថដែលអាចធ្វើអោយជំងឺនោះឆាប់ជាសះស្បើយបាន ប៉ុន្តែការព្យាបាលរោគដោយប្រើប្រាស់ឱសថ(ថ្នាំសម្រាប់កែរោគ) យើងសង្កេតឃើញតាមការប្រើវិធីពីរយ៉ាង ទីមួយគឺតាមបែបសម័យទំនើប មានការប្រើប្រាស់ថ្នាំសេរ៉ូម ថ្នាំគ្រាប់ដែលផ្សំពីម្សៅ លាយជាមួយនិងរុក្ខជាតិផ្សេងៗ។ល។ ទីពីរគឺតាមបែបបុរាណដោយប្រើមើមឈើ ដើមឈើសម្បកឈើ ផ្កា ផ្លែ ស្លឹក ឬស របស់រុក្ខជាតិទាំងឡាយដែលមានគុណប្រយោជន៍យកមកធ្វើជាឱសថបាន។

ប៉ុន្តែនៅក្នុងទីនេះខ្ញុំសូមលើកយកការព្យាបាលតាមបែបបុរាណមកសិក្សាតែប៉ុណ្ណោះជាពិសេសក្នុងសម័យអង្គរ។ ខ្មែរពីសម័យមុនមានតែកាប្រើប្រាស់ថ្នាំបុរាណសឹងតែគ្រប់គ្រួសារ ដោយថ្នាំទាំងនោះជារុក្ខជាតិដុះជុំវិញផ្ទះ និងស្ថិតនៅក្នុងព្រៃមួយចំនួនទៀត។ ឯការផ្សំថ្នាំវិញសុទ្ធតែចេះចាំពីក្បួនតៗគ្នា ដែលច្បាប់អាចចារទុកក្នុងសាស្ត្រាស្លឹករឹត ឬមានការកត់ទុកតៗគ្នាឬក៏ចាំពីគ្នាទៅវិញទៅមក ចំណែកអ្នកដែលចងក្រងនោះគ្មាននរណាក្រៅពីគ្រូថ្នាំនោះ

ទេ ។ នៅក្នុងសាស្ត្រស្លឹករឹតមួយដែលជាការប្រែសម្រួលរបស់លោកគ្រូ **វ៉ាង ចាន់សារ៉ែន** ពីភាសារសុរិន្ទ្រនូវក្បួនថ្នាំសម្រាប់ដោះអំពើនិងព្យាបាលជម្ងឺ ដែលជាវិជ្ជាពេទ្យបែបបុរាណដោយមានសេចក្ដីថា៖

❋បើត្រូវអំពើរពីនរណាម្នាក់នោះត្រូវយក៖

- ដើមស្លាទឹក១
- ដើមក្ដាំងា១ដុសផឹកវាដេញចេញហោង។

❋ ថ្នាំដោះអំពើស្បែកក្ដី ឆ្លោងទឹកក្ដី ឆ្លោងខ្យល់ក្ដីអោយយក៖

- សំបកធ្មារ១
- ឬសស្មៅកន្ត្រើយ១
- គ្រាប់ត្រលាច១ ស្ងោផឹកជាហោង។

❋ថ្នាំដាច់កន្ទុយលិនក្ដី សុកសកក្ដី ឈាមឡើងក្ដី៖

- យកឬសកប្បាសមួយខួប១
- ឬសកន្ទាំងបាយស១
- ម្រេច១
- ទងម្លូរស្រុក៧
- ទងម្លូព្រៃ៧ បុកចូលគ្នាដាក់ស្រាផឹកជាហោង។

❋ថ្នាំដោះអំពើដុំក្នុងពោះឈើចាក់ស្បៀត ៖

- យកឬសម្កាក់ព្រៃទទឹងថ្ងៃ១

- ឬសម្រុំ១ ដុសនិងទឹកក្តៅក៏បាន ស្រាក៏បានជាហោង ។

ក្រៅពីក្បួនថ្នាំទាំងនេះក៏នៅមានក្បួនម្យ៉ាងទៀតដែលស្តីពីស្កន់ជាន់ឈ្មោះ ស្កន់ខ្លែងស្រាក ស្កន់ម្តាយដើម ជំងឺអុតធំជាដើម (រូបលេខ១-រូបលេខ២) ។

អ្វីដែលខ្ញុំលើកលើងមកនេះគឺចង់បញ្ជាក់ថា ការនិយមបែបនេះមានតាំងពីយូរយាណាស់មកហើយដែលគេនិយមប្រើប្រាស់ឱសថបុរាណដូចមានក្នុងក្បួនខាងលើស្រាប់ គឺសុទ្ធតែជារុក្ខជាតិប្រភេទដើម មើម ឬស យកមកផ្សំលាយគ្នា បង្កើតបានជាឱសថមានប្រសិទ្ធភាពខ្ពស់បំផុត ។ បើយើងសម្លឹងមើលនៅស.វទី១២ ក្នុងរាជព្រះបាទជ័យវរ្ម័នទី៧( ១១៨១- ១២១៩)ជាក្សត្រមួយអង្គដែលមានភាពលេចធ្លោល្បីល្បាញរន្ទឺព្រះនាម តាមរយៈព្រះហ្ឫទ័យទុកដាក់ដល់សុខទុក្ខប្រជារាស្ត្រជាធំ ដែលមានសិលាចារឹក**តាព្រហ្ម** (សៀមរាប)បានថែងសរសើរពីទ្រង់យ៉ាងស្ញោក ។ ទន្ទឹមនឹងនេះការលើកស្ទួយយ៉ាងខ្លាំងចំពោះផ្នែកសុខាភិបាល ដោយទ្រង់បានកសាងអារោគ្យសាលា (មន្ទីរពេទ្យ )ជាច្រើនរហូតទៅដល់១០២កន្លែងដែលមានក្នុងក្រុងខ្លះ និងក្រៅក្រុងខ្លះតាមជនបទខេត្តផ្សេងៗ។ លើសពីនេះទៅទៀតបុរសស្ត្រីចំនួន៨១៦៤០នាក់ មកពីភូមិចំនួន៨៣៨(ជាអ្នកធ្វើការនៅតាមមន្ទីរទាំងនោះ និងអ្នកដែលគ្មានទេព្តាក្នុងចិត្ត គេ

ត្រូវជួយព្យាបាល និងជួយផ្គត់ផ្គង់អង្ករ ដែលត្រូវចំណាយអង្ករទាំងអស់១១៩២០០ជារៀងរាល់ឆ្នាំ ។ ការណ៍ទាំងនេះយើងឃើញមាននៅក្នុងសិលាចារឹក**ប្រាសាទតាព្រហ្ម** និងចំនួនមន្ទីរពេទ្យយ៉ាងច្បាស់នៅក្នុងស្លោក ថាមន្ទីរពេទ្យចំនួន១០២ទូរទាំងអាណាខេត្តនានា ហើយទេវរូបចំនួន៧៩០អង្គដែលបានតម្កល់ទុកនៅតាមមន្ទីរពេទ្យទាំងនោះ ។ ក្រៅពីសិលាចារឹកនេះការបញ្ជាក់ពីចំនួនមន្ទីរពេទ្យ ឬ អារោគ្យសាលា គឺយើងក៏អាចដឹងបានតាមរយៈសិលាចារឹក**ស្វាយហ្ស៊ុដ**ដែលស្ថិតនៅប្រទេសឡាវសព្វថ្ងៃ ខ្លឹមសារនៃសិលាចារឹកនោះមានសេចក្តីប្រកាសរបស់មន្ទីព្យាបាលនោះគឺ ផ្តើមដោយការរំលឹកគុណព្រះរតនៈត្រៃ និងបន្ទាប់មកមានការសរសើរពីព្រះមហាក្សត្រស្រេចហើយទើបនិយាយពីកិច្ចការងារផ្សេងៗក្នុងអារោគ្យសាលា ដែលមានគ្រូពេទ្យជាអ្នករៀបចំដង្វាយព្រះពុទ្ធ អ្នកចែកថ្នាំដល់អ្នកជំងឺ អ្នកបុកថ្នាំ អ្នកដាំទឹកក្តៅ អ្នកបុកស្រូវសម្រាប់យកមកផ្គត់ផ្គង់មន្ទីពេទ្យនោះ និងកំណត់ត្រានូវវត្ថុដែលត្រូវតែប្រើប្រាស់រាល់ថ្ងៃដែលត្រូវពឹងឃ្លាំងរបស់ស្តេចទាំងអស់ សុទ្ធតែជាគ្រឿងផ្សំជាឱសថផ្សេងៗមានទឹកឃ្មុំ ស្ករ កប្បូរ ល្ង តៃឡាត់ខ្មៅ ឡាវហាវ វ៉ាន់ស៊ុយ ផាក់ជី ក្រវាញ ខ្ញី សំបោរល្វែង ជាដើម។

ឯការព្យាបាលនៅសម័យនោះគេព្យាបាលតាមពីរបៀបៈ

**១.ការព្យាបាលដោយជីកដ៏ពិសិដ្ឋ**

នៅក្នុងសម្រង់អត្ថបទសិលាចារឹក **តាព្រហ្ម** ខាងលើយើងឃើញមានពាក្យថា ***អ្នកគ្មានទេព្តាមកគង់ក្នុងចិត្ត*** ពាក្យនេះមានន័យថាអ្នកដែលមានជំងឺ ដូច្នេះគេត្រូវតែអរធនាទេព្តាអោយមកគង់ក្នុងចិត្ត ដើម្បីមកព្យាបាលជំងឺដោយប្រើប្រាស់ទឹកពិសិដ្ឋ[១៤]។ ប៉ុន្តែទឹកពិសិដ្ឋ ដែលអ្នកខេត្តសៀមរាបមានជំនឿយ៉ាងមុតមាំ លើការព្យាបាលតាំងពីបុរាណកាលទល់មកដល់បច្ចុប្បន្ន គឺ**ប្រាសាទនាគព ន្ធ័** រឿងតាំងអស់នេះ តែងបានដក់ជាប់របត់គនិតរបស់អ្នកសៀមរាប គឺរឿងព្រេងមួយដែលគេតែងនិយាយតៗគ្នាពីប្រាសាទនាគពន្ធ័នេះថា ជាកន្លែងដែលគេត្រាំរុក្ខជាតិទាំងឡាយអាចធ្វើជាឱសថបាន នៅក្នុងស្រះទឹកពទ្ធ័ជុំវិញប្រាសាទ ។

នៅសិលាចារឹក**ប្រាសាទព្រះខ័ន**K៩០៨ នៅត្រង់ល្បះទី៤១ បាននិយាយអំពី " កោះដ៏ឧត្តុងឧត្តមមួយលេចស្រស់ ចែងចាំឡើងអំពីស្រះទាំងឡាយ(នៅជុំវិញនោះ) ហើយមានលាងជម្រែះភក់ជ្រាំបាបកម្មដល់អ្នកដែលមកដល់ទីនោះ" ក្នុងន័យនេះចង់បង្ហាញពីប្រាសាទនាគពន្ធ័ដែលជាកន្លែងជម្រុះជម្រះនូវរោគទាំងឡាយចោល

ទៅទីនោះ(ដោយទឹកដ៏ពិសិដ្ឋ)[៩]។ ប្រាសាទនាគព័ន្ធត្រូវបានកសាង

ឡើងនៅកណ្តាលអាងទឹកមួយ មានប៉មមួយ(ប្រាសាទហោរា)សាងលើខឿនដែលមានរូបនាគពីរព័ទ្ធជុំវិញ នេះទំនងដោយសារតែនាគ

---

*៩ សូមអានបណ្ដាញវប្បធម៌ពតិមានខ្មែរលេខ ៣ យសោធរ*

ពីរនេះហើយបានជាគេហៅថា ( នាគព័ន្ធ) ដូច្នេះ(រូបលេខ៣៥-៣៦) ។ ប្រាសាទនេះសង់លើបារាយណ៍ឈ្មោះថា " វាលរាជដាក" (ឈ្មោះភាសាដើមសំស្ក្រឹតគឺ ជ័យតដាត) នៅជុំវិញតាមទិសធំទាំងបួន ជុំវិញនោះមានអាងតូចៗបួន តំណាងអោយទន្លេទាំងបួនក្នុងទេវកថាឥណ្ឌាដែ លភ្ជាប់ពីអាងទឹកធំកណ្តាលតាមរយៈចំពួយទឹកដែលមានរូបរាងប្លែកៗពីគ្នា ខាងកើតមានរូបក្បាលមនុស្ស(ទន្លេគង្គា) ខាងត្បូងរូបក្បាលសិង្ហ(ទន្លេសិន្ធុ) ខាងលិចរូបក្បាលសេះ(អមុទរ្យា) ខាងជើងរូបក្បាល់ដំរី(ទន្លេសីតា) (រូបលេខ៣៧-៤០) ដែលហូរច្រោះចេញពីព្រះកេសាព្រះឥសូរ ហើយមានប្រភពមកពីអនោតស្រះនាស្តានសួគ៌ា ។



រូបលេខ៖៣៥-៣៦តួប៉មកណ្តាលនៅរដូវប្រាំ



រូបលេខ៣៧-៤០៖ទរបង្ហូរទឹកទាំងបួនទិសចេញពីប៉មកណ្តាល

ទឹកដ៏ពិសិទ្ធិនេះដដែលនៅក្នុងព្រះពុទ្ធសានាមហាយាន្ត្រ គឺជាទឹកដែលហូរចេញមកពីភ្នំហាមពាន្ត បានជា**ស្រះអនវតប្ត** (អនោតស្រះ) ដែលរីងស្ងួតក្រោយបង្អស់លោកនេះ។ មូលហេតុដែលពោលដូច្នេះ ដោយសារយោងទៅតាមការឧទ្ទិសថ្វាយ ប្រាសាទនេះទៅដល់ព្រះពោធិសត្វលោកស្វរ(ទេពសង្គ្រោះលោក) (រូបលេខ៤១-៤២) ។ បច្ចុប្បន្នយើងឃើញនៅសល់តែរូបសេះនឹងមនុស្ស ដែលតំណាងអោយសេះ**ពាលាហៈ**(រូបលេខ) ដែលជាអវតារបស់**ព្រះពោធិលោកស្វរ**:ដោយមានរឿងដំណាលពីអ្នកសំពៅរងគ្រោះនៅលើកោះមួយដោយសារចាញ់បោកយក្ខិណីមួយហ្វូង ប៉ុន្តែត្រូវបានព្រះពោធិសត្វលោកេស្វរ តំណែងខ្លួនជាសេះហើយសង្គ្រោះមនុស្សទាំងអស់នៅលើកោះនោះអោយរួចផុតមរណា (រូបលេខ) ។មកដល់បច្ចុប្បន្ន គេតែងមានជំនឿទៅលើប្រាសាទនាគព័ន្ធ នេះដដែលខ្លាំងទោះបី ជាពួកគាត់មិនបានស្គាល់ពីទេវកថាឥណ្ឌាក៏ដោយ ក៏គាត់នៅតែមានជំនឿយ៉ាងមុតមាំលើព្យាបាលជំងឺ បើគេចូលទៅក្នុងប្រាសាទបន់ស្រន់ដឹងថាខ្វះធាតុអ្វីមួយ គេត្រូវទៅដងទឹកនៅក្នុងអាងទឹកទាំងបួននោះមកងូតនិងបរិភោគប្រាកដជាជាសះស្បើយមិនខា។



រូបលេខ៤១-៤២៖រូបសេះពាលាហៈដែលសន្តោងពួកឈ្មួញសំពៅ

សូម្បីតែពិធីបួងសួងសុំទឹកភ្លៀងពេលកើតគ្រោះរាំង ក៏គេតែងប្រារព្ធនៅនាគពន្ធ័នេះដែរ ប្រសិនបើគេទៅបួងសួងនៅកន្លែងផ្សេងៗ វាមិនបានលទ្ធផលឆាប់ឆុតដូចប្រាសាទនាគពន្ធ័នេះទេ ។ ប្រាសាទនេះទៀតសោតក៏មានតម្កល់បដិមាជាគ្រឿងការពារនគរមួយព្រះអង្គនៅកណ្តាលប្រាង្គនាគព័ន្ធ នៅពេលដែលសៀមវាយក្រុងអង្គរឆ្នាំ**១៤៣១** សៀមបានវាយបំផ្លាញប្រាសាទនាគព័ន្ធមុនគេហើយទើបពួកគេចូលវវាយក្រុងអង្គរតែម្តង ដោយគេគិតថាព្រះបដិមាទ្រង់គ្រឿងតម្កល់នៅទីនោះ ជាបេះដូងនៃនគរនាខ្មែរ ។ បើយោងតាមពង្សាវតាសៀម សៀមបាននាំយកបដិមានោះព្រមទាំងរូបឆ្មាំ នឹងរូបដំរីទៅក្រុងស្រីអយុធ្យាទៀតផង ។ នៅសម័យក្រោយមកនៅស.វទី**១៦** នៅពេលដែលភូមាបានចូលឈ្លានពានក្រុងអយុធ្យា ពេលនោះបដិមានឹងរូបផ្សេងៗទៀតត្រូវបានគេយកទៅប្រទេស **ភូមា** រួចគេយកទៅតម្កល់ទុកនៅក្នុងទីក្រុង**មន្តលេ** ប្រទេស**ភូមា**សព្វថ្ងៃ។[១០]

## ២.ការព្យាបាលដោយថ្នាំ

ជម្រើសទីពីរក្នុងការព្យាបាលជំងឺ ដោយប្រើថ្នាំមកព្យាបាលដែលជាការផ្សំគ្នារ វាងរុក្ខជាតិមានប្រយោជន៍ជាច្រើនជាមួយទឹកឃ្មុំ សូនជាគ្រាប់ជាដើម ។ នៅក្នុងសិលាចារឹក**តាព្រហ្ម**

---

១០ សូមអានប្រវត្តិសាស្ត្រខ្មែរ ដេវីឌ ឆេណ្ឌលែរ ២០០៥

ដដែលបានបញ្ជាក់ពីចំនួនមនុស្សធ្វើការផ្នែកឱសថជាច្រើននា
សម័យនោះមាន ៖

ក្នុងមួយឆ្នាំអស់ស្រូវ ១១.១៩២ តោនត្រូវភូមិ ទាំង៨៣៨ សឹងមានមនុស្ស ៨១.៦៤០ ជាអ្នកចេញ មន្ទីរព្យាបាលទាំអស់ប្រើអស់ ល្ង ២.១២៤ គីឡូក្រាម ក្រវាញ ១០៥ គីឡូក្រាម គ្រាប់តៃទ្បាត់ ៣.៤០១ គ្រប់ ថ្នាំគ្រុន៤៨.០០០គ្រាប់ ថ្នាំបិទឫដូងបាទ ១.៨៦០ប្រអប់របស់ឯទៀតក្រៅពីប៉ុន្មានមុខនេះ ដូចគ្នាក្នុងប្រកាសរោងព្យាបាលមុន។ បើនិយាយពីរុក្ខជាតិថ្នាំសម្រាប់ផលិតឱសថ គេច្រើនតែនិយមទៅរកនៅប្រាសាទនាគព័ន្ធមានដូចជា៖ វល្លិ៍ប្រេង ឥសីផ្សំស្រេច ទៀលស្វា ត្រយឹង ខ្ចាស់ វល្លិ៍គុយ ពពាលខែ កញ្ជើបាយដាច ស្វាយកកិត ព្រះដង្កាប់ អង្រ្គង សង្ឃរ័ ទៀត រវៀង អណ្តាតក្រពួត ត្រលំប៉េ ឈើភ្លើង ពង្រ ចំបក់ វល្លិ៍មាស ប៉ប្រើស អំពោះ ម្កាក់ព្រៃ អង្រៃដែក ក្របៅ ខ្នុរព្រៃ ជ្រៃក្រឹម ប្រស់ កន្ទួតព្រៃ ខ្ទម្ព គុំភ្លៀង អញ្ចាញ ខ្លែងគង់ អង្កោល ខ្ទិត ស្រម៉ ក្រឡាញ់ ព្រះកម្ចាត់ ជាច្រើនដុះនៅជុំវិញបរិវេណនោះ ហាក់ដូចជាដើមថ្នាំដែលមាននៅតំបន់អង្គរមកដុះនៅនាគព័ន្ធទាំងអស់។ ទាំងអស់នេះគឺសបញ្ជាក់អោយឃើញនៅសម័យបុរាណគេនិយមប្រើឱសថបុរាណខ្លាំងក្លាណាស់ដែរ ។

# ជំពូកា៤ គ្រូជំបង្អស់ក្នុងវិស័យវេជ្ជសាស្ត្រខ្មែរបុរាណ

*អ្វីដែលគួរអោយចាប់អារម្មណ៍បំផុតនោះគឺ នៅតាមមន្ទីរពេទ្យទាំង១០២កន្លែងសុទ្ធតែមានហោបន់ស្រន់ ឬមណ្ឌប(រូបលេខ)ជាប់ជានិច្ច ដែលនៅក្នុងហោបន់ស្រន់នីមួយៗតែងមានតម្កល់ព្រះពុទ្ធរូបមួយអង្គ***ព្រះជាមភៃសជ្យគុរុ***(គ្រូថ្នាំ)(រូបលេខ៤៣) ដែលជាគ្រូថ្នាំដ៏ពូកែសក្តិសិទ្ធិ អាចព្យាបាលរោគទាំងអស់អោយជាសះស្បើយយ៉ាងឆាប់រហ័ស ដោយក្រឡភេសជ្ជៈតូចមួយនៅខាងព្រះហស្តព្រះអង្គ (រូបលេខ) ។ រឿងនេះមិនមែនកើតឡើង ដោយចៃដន្យឡើយ ។ គេចាត់ទុកព្រះពុទ្ធរូបក្នុងសាសនាមហាយានអង្គនេះជាគ្រូថ្នាំ ហើយក៏មិនមែនជាការសន្មត់ដាក់ឈ្មោះទៅតាមការនឹកឃើញទេ រឿងនេះតោងអោយយើងស្វែងយល់ពីប្រវត្តិបុព្វកម្មនៃព្រះពុទ្ធអង្គនេះសិន ទើបយើងងាយស្រួលយល់នូវបញ្ហានេះ។*



*រូបលេខ៤៣៖ក្រឡថ្នាំទិព្វនៅក្នុងព្រះហស្តព្រះភៃសជ្យគុរុ*

នៅក្នុងគម្ពីរសំស្ក្រឹតមួយដែលបានទទួលឥទ្ធិពលពីពុទ្ធសាសន និកាយមហាយាន ដែលមានព្រះសូត្រមួយស្តែងរៀបរាប់ពីប្រវត្តិនៃ ព្រះពុទ្ធអង្គនេះ ដែលមានក្នុងផែនដីផ្សេងទៀត ដូចមានសេចក្តីចែង យ៉ាងច្បាស់ពី **ព្រះពុទ្ធភៃសជ្យគុរុវៃទូរ្យប្រភរាជាមូលបណិធាន សូត្រ** ដែលមានសេចក្តីទាំងស្រុងថា៖

## ១.ពុទ្ធភៃសជ្យគុរុទុរ្យប្រភរាចាមូលបណិធានសូត្រ

សម័យមួយ ព្រះពុទ្ធដ៏មានព្រះភាគ សក្យមុនី គង់ប្រថាប់ ក្នុងក្រុងវេសាលីសុខវិហារ មួយអន្លើដោយព្រះមហាសាវ័ក ៨,០០០ អង្គ ព្រះពោធិសត្វ ៣៦,០០០ អង្គ និងព្រះរាជាធិបតី សេនាអាមាត្យ រហូតដល់ពួកទេវតា។ ខណៈនោះ ឯង**ព្រះមញ្ជុស្រី** អ្នកធម្មរាជបុត្រ អាស្រ័យ **ព្រះពុទ្ធាភិជីហារ** ក្រោកចាកទីអង្គុយមានចីពរឆៀងស្មា ម្ខាងលុតជង្គង់លើផែនដី ចំពោះព្រះភក្ត្ររបស់ព្រះលោកនាថផ្គង អញ្ជលីក្រាបទូលថា៖

បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គប្រោសប្រទានព្រះ ធម្មទេសនាព្រះពុទ្ធនាម និងមហាមូលបនិធាន និងគុណវិសេស យ៉ាងឧិឡារនៃព្រះសម្មាសម្ពុទ្ធទាំងឡាយ ដើម្បីញ៉ាំងអ្នកស្តាប់ធម្ម កថានេះឲ្យបាននៅហិតប្រយោជន៍ទម្លុះដល់សុខភូមិ។

*ព្រះបរមសាស្តា កាលដែលព្រះមញ្ជុស្រីពោធិសត្វ អារាធនាហើយទើបទ្រង់សសើរ ព្រះកិត្តិគុណព្រះភៃសជ្យគុរុពុទ្ធជាម្ចាស់ថា៖*

*ម្នាលកុលបុត្រ អំពីទីនេះទៅផ្លូវទិសបូព៌កន្លងលោកធាតុ ដែលមានចំនួនដូចគ្រាប់ក្នុងគង្គានទី ១០ ។ នទី រួមគ្នាក្នុងទីនោះមាន លោកធាតុមួយឈ្មោះថា* **វិសុទ្ធវៃឌូរ្យលោកធាតុ**។ *ក្នុងលោកធាតុនោះ មានព្រះពុទ្ធមួយព្រះអង្គមាននាមថា* **ព្រះភៃសជ្យគុរុវៃឌូរ្យប្រែកការាជតថាគត** *ព្រះអង្គជាព្រះអរហន្ត ជាអ្នកត្រាស់ដឹងដោយប្រពៃចំពោះអង្គឯង ជាអ្នកបរិបូរណ៍ដោយវិជ្ជា និងចរណៈទ្រង់យាងទៅដោយល្អ ជាអ្នកជ្រាបច្បាស់នូវលោក ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មាន ជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ជាអ្នកត្រាស់ដឹង ជាអ្នកចំណែកធម៌ដល់ពពួកសត្វ។ ម្នាលមញ្ជុស្រីក្នុងអតីតកាល កាលព្រះតថាគតអង្គនោះនៅជាព្រះពោធិសត្វ បំពេញបារមីនៅឡើយព្រះអង្គទ្រង់តាំងបណិធាន ១២ប្រការ ដើម្បីញ៉ាំងសេចក្តីរបស់សព្វសត្វ អោយបានសម្រេច។*

*មហាបណិធាន១២ តើដូចម្តេច?*

*១. ក្នុងកាលដែលយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណសឹងមានព្រះវរកាយដ៏រុងរឿង គ្រប់គ្រាន់ទូរទាំង*

អនន្តលោកធាតុ បិបូរណ៍ដោយមហាបុរិសលក្ខណៈ៣២ ប្រការនិង អនុព្យញ្ជន៨០ ប្រការ សូមឲ្យសព្វសត្វចូរមានវរកាយដូចជាយើង។

២. ក្នុងកាលដែលយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ សូមអោយវរកាយរបស់យើងមានពណ៌ ដូចកែវពិទូរ្យ មានរស្មីរុងរឿងជោតនាការ ជាងព្រះច័ន្ទនិងព្រះអាទិត្យ ប្រដាប់ដោយគុណាលង្ការ ដែលមហាឡារវិសាលដ៏ជ្រៅ សត្វដែលធ្លាក់ទៅកាន់អបាយគទិ សូមអោយរួចបានទៅកាន់ សុគតិតាមប្រាថ្នា។

៣. ក្នុងកាលដែលយើងបានសម្រេចនូវអនុត្តរសម្មាមសម្ពោធិញ្ញាណ សូមឲ្យបានប្រើបញ្ញាកោសល ដ៏ជ្រៅល្អិតសុខុម មិនមានទីបំផុត ញុំាំងសព្វសត្វ អោយបានទទួលនូវភោគសម្បត្តិច្រើនប្រការ កុំមានសេចក្តីទ័លក្រដោយប្រការយ៉ាងណាឡើយ។

៤. ក្នុងកាលដែលយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ប្រសិនបើមានសត្វណាជាមិច្ឆាទិដ្ឋិ ក៏សូមឲ្យយើងញុំាំងសត្វនោះអោយតាំងនៅក្នុងសម្មាទិដ្ឋិក្នុងពោធិមគ្គ ប្រសិនបើសត្វណាមានបដិបទាបែបសាវកយាន បច្ចេកយានក៏សូមអោយយានអាចញុំាំងសត្វនោះមកដំនើរបដិបទាបែបមហាយានវិញ។

៥. ក្នុងកាលដែលយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ប្រសិនមានសព្វសត្វប្រព្រឹត្តព្រហ្មចរិយៈក្នុងធម្មវិន័យរបស់យើង ក៏សូមអោយគេទាំងនោះកុំមានសីលវិបិត្តឡើយ ចូរបរិបូណ៌ដោយអង្គសីលទាំងបីចុះ ប្រសិនបើអ្នកណាមានសីលវិបត្តិកាលបានលឺព្រះនាមយើង ក៏សូមអោយបិបូរណ៌ដូចដើម មិនធ្លាក់ទៅកាន់ទុគតិនិរយាបាយឡើយ។

៦. ក្នុងកាលដែលយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ប្រសិនបើមានសព្វសត្វមានកាយដ៏អាក្រក់មានឥន្រ្ទីយមិនផូរផង់ ល្ងង់ខ្លៅ អប្បប្រាជ្ញា ខ្វាក់ភ្នែក ថ្លង់ គ គម មានព្យាធិទុក្ខផ្សេងៗកាលបានលឺនាមរបស់យើង ក៏សូមអោយបានផុតចាកទុក្ខទាំងពួង ចូរមានបញ្ញាឈ្លាសវៃមាន ឥន្រ្ទិយផូរផង់បរបូណ៌គ្រប់យ៉ាង។

៧. ក្នុងកាលដែលយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ប្រសិនបើមានសព្វសត្វមាន ទុក្ខបៀតបៀន ប្រាសចាកទីពឹងនិងទៅលំនៅអាស្រ័យ ប្រាសចាកពេទ្យនិងថ្នាំ មិនមានញាតិសណ្ដាន ទាល់ក្រ មានទុកលខបៀតបៀនហើយត្រឹមតែនាមនៃយើងក្រឡុងត្រចៀករបស់គេប៉ុណ្ណោះ សូមអោយជំងឺទាំងពួងសះស្បើយទៅ ជាអ្នកមានកាយប្រកបដោយផាសុខភាព និងមានផ្ទះ

សម្បែងជាទីអាស្រ័យ បរបូរណ៍ដោយទ្រព្យរហូតដល់ទីបំផុតបាន សម្រេចដល់ពោធិញ្ញាណ។

៨. ក្នុងកាលដែលយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ប្រសិនបើមានស្ត្រីណា នឿយណាយក្នុងភេទនៃខ្លួន ហើយប្រាថ្នាបាននូវភេទបុរស ត្រឹមបានលឺនាមនៃយើងក៏បាន សម្រេចដូចសេចក្តីប្រាថ្នា រហូតដល់បានជាទីបំផុតក៏ចូលបានជាពោធិញ្ញាណ។

៩. ក្នុងកាលដែលយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ សូមឲ្យយើងអាចញុំាំងនូវសត្វទាំងឡាយអោយរួចនូវអន្ទាក់នៃមារ និងគ្រឿងចំណងរបស់ពួកមិច្ឆាទិដ្ឋិនិងបានបំពេញពោធិចរិយា រហូតដល់ទម្លុះពោធិញ្ញាណដល់ទីបំផុត។

១០. ក្នុងកាលដែលយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ប្រសិនបើមានពួកសត្វណាត្រូវពួកអង្វាត្រូវជាប់ឃុំទទួលទណ្ឌកម្ម ក្នុងពន្ធធានាគារ ឬត្រូវអង្វាដល់ប្រហារជីវិត រហូតដល់ទទួលនូវកាគម្រាមគំហែង មើលងាយជិះជាន់ដទៃៗ ប្រសិនបានលឺនាមយើង អស្រ័យបារមីនិងគុណាភិនីហាររបស់យើង សូមអោយសត្វទាងនោះរួចផុតចាកទុក្ខទាំងពួង។

១១. ក្នុងកាលដែលយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ប្រសិនបើសត្វណាមានសេចក្តីស្រេកឃ្លានព្រោះហេតុនៃអាហារ ប្រសិនបានលឺនាមយើងតាំងចិត្តភាវនាជានិច្ច យើងនិងប្រទានគ្រឿងឧបភោគ បរិភោបគ ដ៏ប្រណិតដល់សត្វពួកនោះ ញុំាំងសត្វទាំងនោះអោយឆ្អែតស្កប់ស្កល់ហើយ នឹងប្រទានធម្មទេសនាអោយដល់សត្វពួកនោះ បានទទួលនូវសេចក្តីសុខ។

១២. ក្នុងកាលដែលយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ប្រសិនបើមានសត្វពួកណា មិនមានគ្រឿងគ្របដណ្តប់ទទួលនូវការរងា និងក្តៅ និងបានរបោម មូសខាំទាំងថ្ងៃទាំងយប់ ប្រសិនបើលឺនាមនៃយើង ភាវនាពិចារណាដល់យើងសោតសត្វនោះនិងបានវត្ថុដែលគេប្រថ្នា។ល។

គ្រានោះព្រះបរមសាស្តាសក្យមុនីពុទ្ធជាម្ចាស់បានត្រាស់តទៅទៀតថា៖

**ព្រះពុទ្ធភៃសជ្យគុរុនេះមានពោធិសត្វធំ២ព្រះអង្គគឺព្រះសុរិយវៃរោចនៈនិងព្រះច័ន្ទវៃរោចនៈ**ជាព្រះពោធិសត្វអ្នកជួយព្រះពុទ្ធភសសជ្យគុរុអង្គនោះ។

ខាងចុងនៃព្រះសូត្រនោះ ទ្រង់សម្តែងអនិសង្សនៃកាបូជាព្រះពុទ្ធភៃសជ្យគុរុអង្គនោះថា៖

អ្នកណានីមួយបានបូជាដល់ព្រះអង្គដោយសេចក្ដីគោរពជ្រះថ្លាក៏និងចម្រើនដោយអាយុ វណ្ណៈ សុខ ពលៈ ប្រាសចាកភ័យវិបត្តិ មិនយល់សប្តិអាក្រក់ សាស្ត្រាវុធទំលាយមិនបាន សត្វសាហាវធ្វើអន្តរាយមិនបាន ពួកចោរធ្វើអន្តរាយមិនបាន ថ្នាំពិសធ្វើអន្តរាយមិនបាន។ល។

ក្រៅពីព្រះអង្គនៅសម្ដែងដល់ពិធីចាត់ មណ្ឌលបបូជា**ព្រះពុទ្ធភៃសជ្យគុរុ**ទៀតថា ត្រូវចាត់ពិធីបូជាគ្រឿងបូជាផ្សេងៗ និងទ្រង់បានប្រទាន គាថាបូជាព្រះគាថានេះ ព្រះបរមសាស្ដា ទ្រង់ប្រថាប់ចូលសមាធិឈ្មោះសវ៌សត្វទុក្ខភិន្ទនាសមាធិ ប្រាកដរស្មីរុងរឿងឡើងលើព្រះកេតុមាលាហើយ ទើបត្រាស់ព្រះគាថាមហាធារណីដូច្នេះ៖

(សំស្រ្កឹតបែបខ្មែរ) នមោ ភគវតេ ភៃសជ្យគុរុ

វៃទូរ្យប្រភរាជាយ តថាគតាយ

អហ៌តេ សម្យក្សម្ពុទ្ធាយ តទយថា

ឪម ភៃសជ្យេ ភៃសជ្យេ ភៃសជ្យេ

សមុទ្គតេ ស្វាហា។

(សេចក្តីប្រែ) សូមឲ្យខ្ញុំ បានសម្រេចនូវជោគជ័យ! ខ្ញុំសូមអ្នកមស្ការ នូវព្រះដ៏មានព្រះភាគ ដែលជាភេសជ្ជគុរុ ដូចចាស្តេចនៃពន្លឺ កែវពិទូរ្យ ជាព្រះតថាគតដែលមានដំណើរល្អយាងទៅកាន់សុគ្គរ

ស្ថាន គឺព្រះនិពាន្ធ ជាព្រះអរហន្ត ដែលទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដោយប្រពៃ ចំពោះព្រះអង្គឯង គ្មានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ឪម ព្រះអង្គជាគ្រូពេទ្យ ជាគ្រូពេទ្យ ជាគ្រូពេទ្យ។

បន្ទាប់ពីត្រាស់គាថាមហាធារណីនេះចប់ហើយ ផែនដីក៏កម្រើកញាប់ញ័រ ពន្លឺភ្លឺព្រោងព្រាតបានប្រាកដឡើង។

ទីបញ្ចាប់នៃព្រះសូត្រទ្រង់ត្រាស់៖

ម្នាលមញ្ជុស្រី បើមានកុលបុត្រ កុលធីតាណា មានព្យាធិទុក្ខបៀតបៀនហើយតាំងចិត្តជាសមាធិ ហើយនាំមហាធារណីបទនេះ បញ្ចុះសេករអាហារឬថ្នាំ ឬក៏ទឹកផឹកឥតគ្រប់១០៨ចប់ហើយទំពារលេបឬផឹកទៅ និងអាចជាសះស្បើយពីព្យាធិបាន។[១១]

ចប់ពុទ្ធភេសជ្ជគុរុវៃទុរ្យប្រភរាជាមូលបណិធានសូត្រ

---

[១១] វ៉ាន់ ចាន់សាវ៉ែន ប្រវត្តិសាងព្រះពុទ្ធភេសជ្ជគុរុ

តាមទស្សនៈបែបពុទ្ធសាសនាមហាយាន ព្រហពុទ្ធដ៏សំខាន់មាន៣ និងមានច្រើនអង្គដែលបានត្រាស់ដឹងដំណាលគ្នា។ ព្រះពុទ្ធ៣អង្គគឺ៖

១. ព្រះសក្យមុនីពុទ្ធជាម្ចាស់

២. ព្រះអមិតាភៈពុទ្ធជាម្ចាស់

៣. ព្រះភៃសជ្យគុរុពុទ្ធាជាម្ចាស់។

តាមក្នុងព្រះពុទ្ធសាសនាបែបថេរវាទយើង មិនអាចមានព្រះពុទ្ធត្រាស់ដឹងឡើងម្តងពីរក្នុងលោកនេះបានឡើយ។ ទោះបីក្នុងអនន្តចក្កវាឡក៏ដោយ។ មិនមែនជាឋានៈដែលព្រះពុទ្ធជាម្ចាស់ត្រាស់ដឹងក្នុងលោកម្តងពីរអង្គនោះទេ។

## ២.ប្រវត្តិសាជ័រូបដិមាព្រះពុទ្ធភៃសជ្យគុរុ

ប្រវត្តិសាង**ព្រះពុទ្ធបដិមាភៃសជ្យគុរុ** ដែលមាននៅក្នុងប្រទេសកម្ពុជាយើងមានតាំងពីសម័យមហានគរភ្នំរហូតមកដល់រជ្ជកាល**ព្រះចាឧស្សូរ្យវ៌្ម័នដី១** ព.ស.**១៥៤៥ - ១៥៩៣** គ.ស. **១០០២-១០៥០**ទ្រង់បានកសាងអាស្រមចំនួន១០០ក្នុងនោះក៏មានអាស្រមមួយ ដែលមានឈ្មោះ**វ្រះសៅគតាត្រម** (អាស្រមព្រះសុគត) គឺវត្តដែលគេហៅក្នុងកាលឥឡូវនេះមកជាវត្ត**ធេពប្រណម្យ** សឹងមាន

ព្រះពុទ្ធរូបព្រះជីវ៍១អង្គ, សន្លឹកសីមាថ្មជាច្រើន និងសិលាចារឹកមួយផែនទៀតនៅក្នុងបិវេណវត្តនេះជាភ័ស្តុតាង។ បដិសង្ខរណ៍ប្រាសាទទេវស្ថាន នៅលើកំពូលភ្នំបាខែង ដែលបានសាងឡើងក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី១ គឺទ្រង់បានជួសជុលនៅផ្នែកខ្លះដែលបាក់បែកទ្រុឌទ្រោម និងកសាងថែមទៀត រៀបចំធ្វើផ្លូវនេះសម្រាប់ឡើងទៅកំពូលភ្នំនេះឲ្យបានស្រួលជាងមុន ព្រោះភ្នំនេះជាគារវស្ថាន ឬជាបូជនីយស្ថានរបស់ព្រះមហាក្សត្រទាំងឡាយ ដែលគង់នៅក្រុងយសោធរបុរៈ។ អ្វីជាពិសេសទ្រង់បានកសាងព្រះពុទ្ធបដិមាភៃសជ្យគុរុផងដែរ។ តាមតម្រាយ័ន្ត១០៨ រៀបរៀងដោយអាចារ្យ ឧរដិន្ត្រ វិរិយបូរណៈជនជាតិថៃ បានរៀបរាប់ពីបញ្ហានេះយ៉ាងច្បាស់។ បុរាណវត្ថុស្ថានទាំងនេះនៅគង់មានរូបរាងជាភស្តុតាងមានមកដល់សព្វថ្ងៃនវជាច្រើន។

ព្រះបាទយសោវរ្ម័នទី១ ស្តេចនៅគ្រងរាជសម្បិត្ត៣៨ឆ្នាំកសោយទីវង្គត រាជបណ្ឌិតថ្វាយព្រះនាម ព្រះបរមសពថា បរមនិវ៌ាណបទ ( បរមនិព្វានបទ) ដោយហេតុទ្រង់និយមក្នុងព្រះពុទ្ធសាសនាជាសំខាន់ ក្នុងព្រះរាជហ្ឫទ័យ។

ដូច្នេះខ្មែរយើងពិតជានិយមសាងព្រះពុទ្ធបដិមា នៃ**ព្រះពុទ្ធភៃសជ្យគុរុ**ណាស់ ក្នុងសម័យបុរាណ លុះមកដល់ខាងក្រោយនៃសម័យមហានគរខ្មែរ គេមិនសូវនិយមទេ។ របៀបកសាងនូវក៏និយមកាន់តែខ្លាំឡើង ក្នុងសុខោទ័យរហូតមកដល់សៀមបច្ចុប្បន្ននេះ។ ពួកគេ

មានជំនឿថាព្រះពុទ្ធបដិមាអង្គនេះ មានអានុភាពសក្តិសិទ្ធិណាស់ សម្រាប់តម្កល់ទុកតាមមន្ទីរពេទ្យនានា ក្នុងការគោរពបូជាសូត្រមន្ត កម្ចាត់នូវជំងឺឧត្បាត និងអហិវាតរោគជាដើម។ ព្រោះព្រះពុទ្ធបដិមា នេះ ត្រូបានបញ្ចុះនូវសេកមន្តប្រភេទអាថព្វវេទបែបព្រះពុទ្ធសាសនា ដែលមាន **មហាយ័ន្ត១០៨ និង ៨ បបម៌១៤ ៨** ដែលសុទ្ធជាកំពូលមន្ត បញ្ចុះក្នុងលោកធាតុទាំង៩ អស់ចំនួន៣ខែ ហើយទើបរកឫក្ស សិត ព្រះបដិមានេះឡើង។ ចំពោះតម្រាសិត ព្រះពុទ្ធបដិមា ព្រភៃសជ្យគុរុ នេះព្រះសង្ឃប្រទេសសៀមបានចំលងយកទៅធ្វើក្នុងពិធិសិតព្រះ មានរហូតមកដល់សព្វថ្ងៃនេះដោយអោយឈ្មោះថា **តម្រាសាជ៍ព្រះ គ្រិជ៍**។ ប្រទេសសៀមបានចាប់ផ្តើមកសាព្រះបដិមាព្រះភៃសជ្យគុរុ តាមប្រទេសកម្ពុជាគ្រាដំបូងក្នុងព.ស.**២៤១១**ហៅព្រះបដិមានេះថា **ព្រះគ្រិជ័បរេស** (រូបលេខ៤៤) ។ ក្នុងកាលនោះសម្តេចព្រះសង្ឃរាជ និងមន្ត្រីសង្ឃនៅប្រទេសសៀម បានឲ្យតម្លៃព្រះពុទ្ធបដិមាភៃសជ្យគុ រុ ដែលបាននាំមកពីប្រទេសកម្ពុជាថាមានអានុភាពខ្លាំងណាស់។ តម្រាព្រះវេទ១០៨ ប្រមូលរៀបរៀងដោយអាចារ្យឧរជិន្ទ្រ វិរិយបូរ ណៈ បញ្ជាក់ថាសម្តេចព្រះវនរ័ត(ដេង) មានអាពាធធ្ងន់ព្រោះអហិវាត រោគ សម្តេចព្រះមហាសមណចៅក្រម ព្រះយាវជិរញាណវរោរស បានអរធនាព្រះពុទ្ធបដិមាភៃសជ្យគុរុ(ព្រះក្រិង) ដែលកសាងដោយ ខ្មែរសម័យមហានគរ ទ្រង់អធិស្ឋានសុំទឹកមន្តប្រគេនសម្តេច ព្រះ វនរ័តឆាន់។ កាលបានឆាន់ទឹកមន្តជំងឺនោះក៏ជាតាមលំដាប់រហូត បានសោះស្បើយដូចដើម។



*រូបលេខ៤៤៖ព្រះក្រិងនៅប្រទេសថៃនិងនៅប្រទេសកម្ពុជាបច្ចុប្បន្ន*

## ៣. របៀបសាងព្រះពុទ្ធបដិមាភៃសជ្យគុរុ

*បុព្វបុរសខ្មែរសម័យបុរាណ កាលចាត់ចែងកសាងព្រះពុទ្ធបដិមាអង្គនេះ តែងសាងដោយលោហធាតុ៩ប្រភេទ មាស ប្រាក់ ដែក លង្ហិន ទង់ដែង ស្ពាន់ ទង់ហ្វា សំណ សំរិទ្ធ ផែជាបន្ទះស្តើងៗ ហើយយកពេលវាលានក្ខត្តឫក្សដ៏សមគួរ ចារមន្តបញ្ចុះនិងបន្ទះលោហធាតុទាំងនោះ ហើយសូធ្យសេកព្រះបរិត្តនិងមន្តវិជ្ជាមួយចំនួនមានមន្តបណ្តូលព្រះពុទ្ធជាដើម ។ មន្តទាំងនោះ ជាបណ្តូលព្រះពុទ្ធគុណ ដូចជា* **អ សំ វិ សុ លោ បុ ស ពុ ភ ឬ ឆ បបមំ** *ជាដើម អស់ចំនួន៣ខែ ទើបចាប់ផ្តើមរកពេលវេលាសិតព្រះពុទ្ធរូប តាមសម័យដ៏គួរតាមឫក្សពេលវេលា។*

## ៤. មន្តយ័ន្តសម្រាប់ចារបញ្ចុះក្នុងបន្ទះលោហធាតុទាំង៩ប្រភេទ

*ឈ្មោះយ័ន្តទាំងនោះមាន៖* បទុមចក្រា ភគវម្បតិ ត្រៃសរណាគមន៍ នវលោកុត្តរធម៌ ព្រះនរា ចតុរារិយសច្ច ព្រះរតនត្រ័យ ចក្រាសិរលោក មកុដព្រះពុទ្ធ ចារមី៣០ សុកិត្តិមា បឋមំ ព្រះ៥អង្គ យ័ន្តអង្គរក្សសោឡសមង្គល ព្រះពុទ្ធ២៨អង្គ ឃដេសិ ព្រះពុទ្ធគុណ ព្រះនវភា ជជាព្រហ្ម និជ ចតុភេ។ *រួមទាំងយ័ន្ត១០៨ និងយ័ន្តបឋម១៤ ន មានឈ្មោះដូចតទៅ៖*

*ន ប៉ាំងទៅសមុទ្រ ន នាគប្រក់ ន វជិរាវុធ ន ធន់ ន កម្ចាយ ន ប្រាជ្ញាគ្រប់ទិស ន គ្របចក្កវាឡ ន ប៉ាំងត្រៃភព ន ប៉ាំងមេឃា ន ដឹកម្រេីក ន កម្ចាក់ នបិទ ន បិទអាកាស និង ន ឡោមព័ទ្ធ។*

*ក្រៅពីនេះមានចារឹកយ័ន្ត១០ ទិសនិងយ័ន្ត១០ ទៀតដើម្បីការពារជុំវិញ សម្រាប់ក្នុងមណ្ឌលពិធី។ កាលយ័ន្តសម្រេចហើយ ឲ្យសេកគាថាហៅយ័ន្ត ឪង្ការព្រះពុទ្ធព្រះគុណ ឪង្ការនមោពុទ្ធាយជាដើម។*

































# ប្រវត្តិរូបសង្ខេប

- **រឹម និស្សបញ្ញា** កើតនៅថ្ងៃអាទិត្យ ៨រោច ខែជេស្ឋ ឆ្នាំជូត ព.ស២៥៣៩ ត្រូវនឹងថ្ងៃអាទិត្យ ទី០៩ ខែមិថុនា ឆ្នាំ១៩៩៦ នៅភូមិម័ល សង្កាត់ ដង្កោ ខណ្ឌដង្កោ ក្រុងភ្នំពេញ រាជធានីភ្នំ។
- មាតានាម **ឡុង ចន្ធី**
- បិតានាម **ឡុច ស៊ីមុន្ថា**
- បច្ចុប្បន្នភាព ជានិស្សិតអក្សរសាស្ត្រខ្មែរឆ្នាំទី០៤នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាគ្រូបង្រៀនព្រះវិន័យនៅវត្តសំបួរមាស ។

ISBN-978-9924-9140-0-6

©រក្សាសិទ្ធិគ្រប់យ៉ាង